សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស
លីកាដូ

LICADHO

CAMBODIAN LEAGUE FOR THE
PROMOTION AND DEFENSE OF
HUMAN RIGHTS



# គ្មានប្រកសុវត្ថិភាព៖

## បរាជ័យក្នុងការទប់ស្កាត់ឃាតកម្មដោយដៃគូស្និទ្ធស្នាល

របាយការណ៍ចេញផ្សាយ
ខែមីនា ឆ្នាំ២០២៣

# គ្មានច្រកសុវត្ថិភាព៖

## បរាជ័យក្នុងការទប់ស្កាត់ឃាតកម្មដោយដៃគូស្និទ្ធស្នាល

របាយការណ៍ចេញផ្សាយ ខែមីនា ឆ្នាំ២០២៣

**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស  លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស
# (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើត ឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិ នយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ការគោរពសិទ្ធិទាំងនេះពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវ សមិទ្ធិផលល្អក្នុងអតីតកាល លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលស្ថានភាពសង្គមតាមរយៈកម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស ពីការិយាល័យកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងនៅតាមសាខាទាំង ១២ ខេត្តផ្សេងទៀត។

**កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស** | **កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ**

### ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ

បុគ្គលិកអង្គការលីកាដូ ធ្វើការឃ្លាំមើល និងស្រាវជ្រាវលើករណីរំលោភសិទ្ធិមនុស្ស ករណីរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែង តាមរយៈការធ្វើ អន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

### ជំនួយផ្នែកសេវាសុខភាព និងសេវាកម្មសង្គមកិច្ច

ក្រុមគ្រូពេទ្យផ្តល់សេវាសុខភាពដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារនៅជនបទ និងទីក្រុង ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារ ដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសារ របស់អ្នកទាំងនោះ ហើយផ្តល់ជំនួយ សម្ភារៈ និងម្ហូបអាហារ រយៈពេលខ្លី។

### ការប្រឹក្សាផ្នែកច្បាប់ដល់ជនជាប់ឃុំ

អ្នកប្រឹក្សាផ្នែកច្បាប់ ផ្តល់ការប្រឹក្សាដល់ជនជាប់ឃុំនៅពន្ធនាគារនៅជនបទ និងទីក្រុង ដើម្បីធ្វើឲ្យប្រាកដថា ជនជាប់ឃុំទាំងនោះមានតំណាង ផ្នែកច្បាប់ នៅគ្រប់ដំណាក់កាលនៃនីតិវិធីដែលពាក់ព័ន្ធ។

### ការពិគ្រោះយោបល់ផ្នែកច្បាប់

ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការពិគ្រោះយោបល់ផ្នែកច្បាប់ ហើយចំពោះ ករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូន ដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

### គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និង បណ្តាញនានា

ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ដែលរងគ្រោះ ដោយផ្តល់នូវកិច្ចការពារសេវាកម្មផ្នែកច្បាប់ និងសេវាសុខភាព ព្រមទាំងជួយពង្រឹងសមត្ថភាពរបស់អ្នកទាំងនោះ ក្នុងការតស៊ូមតិ។

### ទាក់ទាញមតិគាំទ្រជាសាធារណៈ និងតាមសហគមន៍

ករណីរំលោភសិទ្ធិមនុស្ស ដែលអង្គការលីកាដូបានឃ្លាំមើល និងស្រាវជ្រាវ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិត ជារបាយការណ៍ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។


**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរសព្ទលេខ៖ (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២

អ៊ីម៉ែល៖ licacambodia14@gmail.com
គេហទំព័រ៖ www.licadho-cambodia.org Facebook: www.facebook.com/licadho Email Digest: http://www.licadho-cambodia.org/follow.php

# មាតិកា




សេចក្ដីផ្ដើម ទំព័រ១

សេចក្ដីសង្ខេបនៃការរកឃើញសំខាន់ៗ ទំព័រ២

វិធីសាស្ត្រ ទំព័រ៣

ដែនកំណត់ ទំព័រ៣

ការរកឃើញ ទំព័រ៤

- សេចក្ដីសង្ខេបនៃករណី ៤
- ការទទួលបានយុត្តិធម៌មិនដូចគ្នា សូម្បីតែចំពោះអំពើឃាតកម្ម ៥
- អំពើហិង្សាដែលបង្កឡើងដោយបទដ្ឋានយេនឌ័រ និងវប្បធម៌នៃការគ្រប់គ្រង ៧
- បញ្ហាប្រឈមក្នុងការរាយការណ៍អំពីអំពើហិង្សា ៩
- ការព្យាយាមចាកចេញ៖ ឧបសគ្គចំពោះការលែងលះ និងរស់នៅបែកគ្នា ១១
- ការព្យាយាមចាកចេញ៖ ការរារាំងដោយការផ្សះផ្សា ១៣
- ភាពបរាជ័យនៃយន្តការការពារ ១៦

សេចក្ដីសន្និដ្ឋាន ទំព័រ១៩

អនុសាសន៍ចំពោះរាជរដ្ឋាភិបាល ទំព័រ២០

# សេចក្ដីផ្ដើម

របាយការណ៍នេះ ត្រូវបានរៀបរៀងឡើង ផ្អែកលើអំពើឃាតកម្មលើស្ត្រីចំនួន ២៦នាក់ ដែលប្រព្រឹត្តដោយប្ដី សង្សារ ឬអតីតដៃគូរបស់ពួកគេ នៅចន្លោះខែមករា ឆ្នាំ២០២០ ដល់ខែមិថុនា ឆ្នាំ២០២២ ។ កុមារ ៥នាក់ និងបុរសម្នាក់ត្រូវបានសម្លាប់ជាមួយនឹងស្ត្រីរងគ្រោះទាំងនេះ ។

តាមរយៈការបង្ហាញអំពីផលវិបាកធ្ងន់ធ្ងរ និងគួរឱ្យរន្ធត់ដែលកើតចេញអំពើហិង្សាក្នុងគ្រួសារ អង្គការលីកាដូព្យាយាមជំរុញឱ្យមានការផ្លាស់ប្ដូរ ដើម្បីដោះស្រាយបញ្ហារបស់ស្ត្រី ដែលប្រឈមមុខនឹងអំពើហិង្សា និងគ្រួសាររបស់ជនរងគ្រោះ ដែលត្រូវបានសម្លាប់ដោយដៃគូស្និទ្ធស្នាលរបស់ពួកគេ ។ បញ្ហាប្រឈម និងការបរាជ័យដែលបានកត់ត្រានៅក្នុងករណីទាំងនេះ អាចអនុវត្តបានចំពោះស្ត្រីជាច្រើនផ្សេងទៀត ដែលកំពុងប្រឈមមុខ ឬនឹងប្រឈមមុខនឹងការរំលោភបំពានផ្លូវកាយ ផ្លូវភេទ សេដ្ឋកិច្ច អារម្មណ៍ ឬផ្លូវចិត្ត ។

អំពើហិង្សាផ្អែកលើយេនឌ័រ គឺជាការរំលោភសិទ្ធិមនុស្សដែលរីករាលដាលលឿនបំផុតនៅក្នុងប្រទេសកម្ពុជា ។ ការស្ទង់មតិនៅក្នុងឆ្នាំ២០១៥ បានរកឃើញថា ២១% នៃស្ត្រីដែលបានស្ទង់មតិក្នុងប្រទេសកម្ពុជាបានជួបប្រទះអំពើហិង្សាផ្លូវកាយ ឬផ្លូវភេទដោយដៃគូស្និទ្ធស្នាល ហើយជិតម្នាក់ក្នុងចំណោមស្ត្រី ៣នាក់ បានរាយការណ៍អំពីអំពើហិង្សាផ្លូវចិត្ត ។[១] នេះគឺជាផ្នែកមួយនៃបញ្ហាសកល ដូចដែលអង្គការសហប្រជាជាតិបានប៉ាន់ប្រមាណក្នុងឆ្នាំ២០២១ ថាស្ត្រីចំនួន ៤៥.០០០នាក់ នៅទូទាំងពិភពលោកត្រូវបានសម្លាប់ក្នុងឆ្នាំនោះដោយដៃគូស្និទ្ធស្នាល ឬសមាជិកគ្រួសារផ្សេងទៀត ។[២]

បទដ្ឋានយេនឌ័រក្នុងប្រទេសកម្ពុជា បន្តគូសបញ្ជាក់ថាអំពើហិង្សាក្នុងគ្រួសារគឺសមហេតុផលនៅក្នុងកាលៈទេសៈមួយចំនួន ។ ការលុបបំបាត់អំពើហិង្សាក្នុងគ្រួសារទាមទារការផ្លាស់ប្ដូរវប្បធម៌រយៈពេលវែងដើម្បីដោះស្រាយបញ្ហាបទដ្ឋានយេនឌ័រ និងវិធានការបន្ទាន់ដើម្បីធានាសុវត្ថិភាព និងស្វ័យភាពរបស់ស្ត្រីគ្រប់រូប ។ រាជរដ្ឋាភិបាល បានខកខានម្ដងហើយម្ដងទៀតក្នុងការដោះស្រាយបញ្ហាទាំងពីរ ។ ការស្នើសុំជំនួយរបស់ស្ត្រីត្រូវបានអាជ្ញាធរបដិសេធជាញឹកញាប់ ។ សេវាកម្មសំខាន់ៗ សម្រាប់ស្ត្រីដែលប្រឈមមុខនឹងអំពើហិង្សាក្នុងគ្រួសារគឺនៅមិនទាន់មាន ឬមិនផ្ដល់ឱ្យបានគ្រប់គ្រាន់ពីរាជរដ្ឋាភិបាល ។

ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ (ច្បាប់ស្ដីពីអំពើហិង្សាក្នុងគ្រួសារ) នៅតែមានចន្លោះប្រហោង និងភាពមិនច្បាស់លាស់ ហើយនីតិវិធីលែងលះដែលគ្មានប្រសិទ្ធភាពធ្វើឱ្យស្ត្រីជាប់អន្ទាក់ក្នុងទំនាក់ទំនងហិង្សា ។

អំពើឃាតកម្មដែលត្រូវបានចងក្រងជាឯកសារនៅក្នុងរបាយការណ៍នេះគឺជាលទ្ធផលនៃបទប្បញ្ញត្តិបន្ធូរបន្ថយ ដែលរួមបញ្ចូលទៅក្នុងក្របខណ្ឌច្បាប់ ដែលមិនមានការអនុវត្តយ៉ាងទូលំទូលាយ ។ ការព្រាង និងការអនុវត្តច្បាប់ស្ដីពីអំពើហិង្សាក្នុងគ្រួសារ បានចំណាយពេលវេលាជាងមួយទសវត្សរ៍ ដោយសារក្ដីបារម្ភដែលបង្ហាញនៅក្នុងសភាថាការអនុម័តរបស់ខ្លួននឹង «ដូចជាបដិវត្តន៍សង្គម» ។[៣] ខណៈពេលដែលរាជរដ្ឋាភិបាល បានប្ដេជ្ញាចិត្តក្នុងការត្រួតពិនិត្យច្បាប់នេះ រាជរដ្ឋាភិបាលបានលើកឡើងថាការត្រួតពិនិត្យរបស់ខ្លួនត្រូវបានពន្យារពេលរហូតដល់ឆ្នាំ២០២២ ដោយសារតែការរីករាលដាលនៃជំងឺកូវីដ-១៩ ។[៤] នៅពេលច្បាប់នេះត្រូវបានបោះពុម្ពផ្សាយ គេពុំឃើញមានការស្នើសុំធ្វើវិសោធនកម្មឡើយ ។

ប្រព័ន្ធការពារ និងការឆ្លើយតបរបស់កម្ពុជាត្រូវតែត្រួតពិនិត្យសារឡើងវិញជាបន្ទាន់ ។ ដោយឈរនៅជាមួយស្ត្រីនិងសកម្មជន អង្គការលីកាដូបាននិងកំពុងអំពាវនាវឱ្យដោះស្រាយបញ្ហាដូចគ្នានេះអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ ។[៥] ប្រសិនបើរាជរដ្ឋាភិបាលនៅតែមិនចាត់វិធានការយ៉ាងទូលំទូលាយ និងមានប្រសិទ្ធភាពដើម្បីដោះស្រាយបញ្ហាទាំងនេះទេ នោះស្ត្រីនិងកុមារនៅកម្ពុជានឹងនៅតែមិនទទួលបានសុវត្ថិភាព ទីភ្នាក់ងារ និងសិទ្ធិរស់រានមានជីវិតរបស់ពួកគេ ។

[១] អ្នកឆ្លើយតបរួមមានស្ត្រីដែលធ្លាប់ស្ថិតក្នុងទំនាក់ទំនងស្នេហា ។ ការស្ទង់មតិជាតិស្ដីពីសុខភាពស្ត្រី និងបទពិសោធន៍ជីវិតនៅកម្ពុជា ក្រសួងកិច្ចការនារី (កកន) ទំព័រ ៤៦ ឆ្នាំ២០១៥ ដកស្រង់ពី៖ https://asiapacific.unwomen.org/en/digital-library/publications/2015/11/national-survey-on-women-s-health-and-life-experiences-in-cambodia

[២] "អំពើឃាតកម្មពាក់ព័ន្ធនឹងយេនឌ័រលើស្ត្រីនិងកុមារី (ឃាតកម្មស្ត្រី/ការសម្លាប់ស្ត្រី)" UNODC និង UN Women ទំព័រ ១៥ ឆ្នាំ២០២២ ដកស្រង់ពី៖ https://www.unwomen.org/sites/default/files/2022-11/Gender-related-killings-of-women-and-girls-improving-data-to-improve-responses -to-femicide-feminicide-en.pdf

[៣] "របាយការណ៍វឌ្ឍនភាពស្ដីពីការអនុវត្តវេទិកាទីក្រុងប៉េកាំងសម្រាប់សកម្មភាពលើបញ្ហាស្ត្រី ១៩៩៥-២០០៥" កកន ទំព័រ១៤ ខែតុលា ឆ្នាំ២០០៤ ដកស្រង់ពី៖ https://www.un.org/womenwatch/daw/Review/responses/CAMBODIA-English.pdf ; Katherine Brickell "ឆ្ពោះទៅរកភូមិសាស្ត្រស្និទ្ធស្នាលនៃសន្តិភាព? ការផ្សះផ្សាក្នុងមូលដ្ឋាននៃអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា" ប្រតិបត្តិការរបស់វិទ្យាស្ថានអ្នកភូមិសាស្ត្រអង់គ្លេស ទំព័រ៣២៧ ឆ្នាំ២០១៥

[៤] "នៅក្នុងកិច្ចសន្ទនាជាមួយកម្ពុជា អ្នកជំនាញនៃគណៈកម្មាធិការសិទ្ធិមនុស្សបានសួរអំពីសេរីភាពនៃការបញ្ចេញមតិនិងលើកបញ្ហាទាក់ទងនឹងវិធានការបង្ការជំងឺកូវីដ-១៩" សេចក្ដីសង្ខេបនៃកិច្ចប្រជុំ ការិយាល័យអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ដកស្រង់ពី៖ https://www.ungeneva.org/en/news-media/meeting-summary/2022/03/dialogue-cambodia-experts-human-rights-committee-ask-about

[៥] សូមមើល "របាយការណ៍ស្ត្រីកម្ពុជា ឆ្នាំ២០០៤៖ សេចក្ដីសង្ខេបអំពីស្ថានភាពស្ត្រីនៅកម្ពុជា" អង្គការលីកាដូ ទំព័រ៨ ខែកក្កដា ឆ្នាំ២០០៤ ដកស្រង់ពី៖ https://www.licadho-cambodia.org/reports.php?perm=56

# សេចក្តីសង្ខេបនៃការរកឃើញសំខាន់ៗ

- អង្គការលីកាដូ បានចងក្រងជាឯកសារពីអំពើឃាតកម្មលើស្ត្រីចំនួន ២៦នាក់ ដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬអតីតដៃគូរបស់ពួកគេ ចាប់ពីខែមករា ឆ្នាំ២០២០ រហូតដល់ខែមិថុនា ឆ្នាំ២០២២ ។ កុមារចំនួន ៥នាក់ និងបុរសម្នាក់ត្រូវបានសម្លាប់ជាមួយនឹងជនរងគ្រោះជាស្ត្រីទាំងនេះ ។

- ក្រៅពីកុមាររងគ្រោះទាំង ៥នាក់នេះ កុមារ ៨នាក់ផ្សេងទៀតបានឃើញម្តាយរបស់ពួកគេត្រូវបានសម្លាប់ដោយផ្ទាល់ភ្នែក ។

- ចំនួនករណីដែលបានចងក្រងដោយអង្គការលីកាដូពាក់ព័ន្ធនឹងការសម្លាប់ដោយដៃគូស្និទ្ធស្នាល បានកើនឡើងនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ។ អ្នកឃ្លាំមើលបានកត់ត្រាស្ត្រីចំនួន ៦នាក់ និងកុមារម្នាក់ត្រូវបានសម្លាប់នៅក្នុង ឆ្នាំ២០២០ ស្ត្រីចំនួន ១៣នាក់ និងកុមារ ៤នាក់ ត្រូវបានសម្លាប់ក្នុង ឆ្នាំ២០២១ និងស្ត្រីចំនួន ៧នាក់ត្រូវបានសម្លាប់ក្នុងឆមាសទីមួយនៃឆ្នាំ២០២២ ។

- ព័ត៌មានដែលប្រមូលបានដោយអ្នកឃ្លាំមើលរបស់អង្គការលីកាដូ បានបង្ហាញថា គិតត្រឹមខែមករា ឆ្នាំ២០២៣ អំពើឃាតកម្មតែ ១៤ករណីប៉ុណ្ណោះ ក្នុងចំណោមអំពើឃាតកម្មសរុប ២៦ករណី ដែលឈានដល់ការកាត់ទោសជនល្មើសពីបទឃាតកម្មដោយផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១០ឆ្នាំ ដែលជាទោសអប្បបរមាសម្រាប់បទល្មើសឃាតកម្មតាមក្រមព្រហ្មទណ្ឌ ។ យ៉ាងហោចណាស់ជនល្មើស ៣នាក់ ត្រូវបានកាត់ទោសពីបទល្មើសមួយចំនួនដែលស្រាលជាងនេះ និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតិចជាង ១០ឆ្នាំ ដោយផ្តន្ទាទោសតិចដោយមិនសមហេតុផល ឬត្រូវបានប្តូរបទចោទប្រកាន់ ឬនិងបន្ធូរបន្ថយការផ្តន្ទាទោសនៅសាលាឧទ្ធរណ៍ ។

- យោងតាមបទសម្ភាសន៍ដែលធ្វើឡើងដោយអង្គការលីកាដូជាមួយសមាជិកគ្រួសារនិងតួអង្គពាក់ព័ន្ធដទៃទៀត យ៉ាងតិចណាស់ស្ត្រីចំនួន ១៦នាក់ ដែលត្រូវបានសម្លាប់ បានជួបប្រទះនូវអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ឬសេដ្ឋកិច្ច ឬអំពើគំរាមកំហែងផ្សេងៗ ។ ស្ទើរតែពាក់កណ្តាលនៃស្ត្រីទាំង ២៦នាក់នេះ ធ្លាប់ជួបប្រទះនូវឧប្បត្តិហេតុនៃអំពើហិង្សាផ្លូវកាយ ។

- យ៉ាងតិចណាស់ ១១ករណី ដែលអាជ្ញាធរមូលដ្ឋាន ឬនគរបាលបានដឹងពីការសម្រេចចិត្តរបស់ស្ត្រីក្នុងការបញ្ចប់ទំនាក់ទំនងគ្រួសារ ឬអាកប្បកិរិយាបែបហិង្សារបស់ដៃគូស្ត្រីទាំងនោះ ប៉ុន្តែមិនបានជួយសម្រួលដល់ការលែងលះគ្នា ឬផ្តល់ការការពារណាមួយនោះដល់ស្ត្រីទាំងនោះទេ ។ អាជ្ញាធរឃុំបានចេញកិច្ចព្រមព្រៀងលែងលះក្នុងករណីចំនួនពីរ ប៉ុន្តែមិនអាចការពារស្ត្រីពីការសងសឹកពីស្វាមីរបស់នាង បន្ទាប់ពីនាងព្យាយាមបញ្ចប់ចំណងអាពាហ៍ពិពាហ៍ ។

- ជនល្មើសយ៉ាងតិចណាស់ចំនួន ៦នាក់ធ្លាប់បានចូលរួមក្នុងការផ្សះផ្សា ការសម្របសម្រួល ឬការអប់រំ ។ ៥នាក់ក្នុងចំណោមអ្នកទាំង ៦នាក់ ចូលរួមក្នុងការផ្សះផ្សាដែលដឹកនាំដោយអាជ្ញាធរ ចំណែកម្នាក់ទៀតទទួលការផ្សះផ្សាដោយគ្រួសារជនល្មើស ។ ការអនុវត្តទាំងនេះនៅតែបរាជ័យក្នុងការបញ្ចប់អំពើហិង្សាក្នុងគ្រួសារ និងរារាំងលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានយុត្តិធម៌ និងសុវត្ថិភាព ។

# វិធីសាស្ត្រ

របាយការណ៍នេះ ផ្ដោតលើ ២៦ករណី ដែលចងក្រងដោយអង្គការលីកាដូ ដែលស្ត្រីត្រូវបានសម្លាប់ដោយដៃគូស្និទ្ធស្នាលបច្ចុប្បន្ន ឬអតីតដៃគូរបស់ពួកគេនៅចន្លោះខែមករា ឆ្នាំ២០២០ រហូតដល់ខែមិថុនា ឆ្នាំ២០២២ ។ ករណីមួយចំនួនដែលកើតឡើងនៅក្នុងរាជធានីភ្នំពេញ និងមួយចំនួនទៀតដែលកើតឡើងក្នុងខេត្តចំនួន១២ ត្រូវបានចងក្រងជាឯកសារដោយផ្អែកលើទីតាំងការិយាល័យរបស់អង្គការលីកាដូ ។[៦] ករណីទាំងនោះត្រូវបានកំណត់ដោយអ្នកឃ្លាំមើលរបស់អង្គការលីកាដូ តាមរយៈពាក្យបណ្ដឹងរបស់សមាជិកគ្រួសារ និងសាច់ញាតិនៃជនរងគ្រោះ បន្ទាប់ពីស្ត្រីទាំងនោះត្រូវបានសម្លាប់ ឬព័ត៌មាននៅលើបណ្ដាញសង្គម ឬការបោះពុម្ពផ្សាយដោយសារអត្ថបទកាសែត និងការបញ្ជូនបន្តពីអាជ្ញាធរ ឬអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត ។

អង្គការលីកាដូ ជួយស្ត្រីដែលប្រឈមមុខនឹងអំពើហិង្សាក្នុងគ្រួសារ ដោយធ្វើការអន្តរាគមន៍ជាមួយអាជ្ញាធរ ការផ្ដល់ប្រឹក្សាយោបល់និងជាតំណាងផ្នែកច្បាប់ ការផ្ដល់ជំនួយផ្នែកវេជ្ជសាស្ត្រ និងការផ្ដល់ជំនួយផ្នែកសេវាសង្គមជាមូលដ្ឋានផ្សេងទៀត និងការបញ្ជូនទៅកាន់អង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត ។ អ្នកឃ្លាំមើលរបស់អង្គការលីកាដូបានស៊ើបអង្កេតករណីទាំងនេះដោយកត់ត្រាអង្គហេតុ និងសម្ភាសសមាជិកគ្រួសារ និងមិត្តភក្តិរបស់ស្ត្រីដែលត្រូវបានសម្លាប់ អ្នកជិតខាង អាជ្ញាធរ មន្ត្រីពន្ធនាគារ និង/ឬសាក្សី ។ ចំពោះករណីដែលបានលើកឡើងក្នុងរបាយការណ៍នេះ អង្គការលីកាដូបានផ្ដល់សេវាកម្មដល់កុមារនិងសមាជិកគ្រួសាររបស់ស្ត្រីដែលត្រូវបានសម្លាប់ ចងក្រងជាឯកសារនូវសកម្មភាពណាមួយដែលធ្វើឡើងដោយអាជ្ញាធរ និងប្រព័ន្ធច្បាប់និងគាំទ្រក្រុមគ្រួសារជនរងគ្រោះក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីស្វែងរកយុត្តិធម៌ ។

បន្ថែមពីលើរបាយការណ៍របស់អ្នកឃ្លាំមើល អង្គការលីកាដូបានធ្វើការសម្ភាសជាបន្តបន្ទាប់ ចំនួន ៨ ពាក់ព័ន្ធនឹងករណី ចំនួន ៦ ដើម្បីប្រមូលព័ត៌មានបន្ថែមសម្រាប់របាយការណ៍នេះ ។ ការសម្ភាសត្រូវបានធ្វើឡើងជាមួយសមាជិកគ្រួសារ និង/ឬមិត្តភក្តិរបស់ស្ត្រីរងគ្រោះនៅក្នុងខែកញ្ញា និងតុលា ឆ្នាំ២០២២ ។ របាយការណ៍នេះក៏បានលើកឡើងនូវចំណេះដឹងរបស់អ្នកឃ្លាំមើលរបស់អង្គការលីកាដូនិងបទពិសោធន៍របស់ពួកគេក្នុងការគាំទ្រស្ត្រីដែលបានជួបប្រទះអំពើហិង្សាក្នុងគ្រួសារក្នុងរយៈពេល ៣ ទសវត្សរ៍កន្លងមកនេះផងដែរ ។

ឈ្មោះនិងព័ត៌មានដែលកំណត់អត្តសញ្ញាណផ្សេងទៀត ត្រូវបានផ្លាស់ប្ដូរ ឬលុបចេញ ដើម្បីធានាសិទ្ធិឯកជនភាពនិងសុវត្ថិភាពរបស់អ្នកចូលរួមផ្ដល់បទសម្ភាសន៍ ។

**ឃុំ-សង្កាត់ ដែលឃាតកម្មត្រូវបានចងក្រង**



# ដែនកំណត់

របាយការណ៍នេះ មិនតំណាងឱ្យករណីទាំងអស់ ឬមិនបង្ហាញពីការកើតមានជាទូទៅនៃអំពើហិង្សាក្នុងគ្រួសារឬអំពើឃាតកម្មដោយដៃគូស្និទ្ធស្នាលនៅក្នុងប្រទេសកម្ពុជាឡើយ ។ ស្ត្រីជាច្រើនប្រឈមមុខនឹងឧបសគ្គជាច្រើននៅក្នុងការរាយការណ៍ពីអំពើហិង្សា។ ចំនួនករណីដែលបានចងក្រងជាឯកសារក្នុងរបាយការណ៍នេះក៏ត្រូវបានកម្រិត ដោយផ្អែកលើទីតាំងការិយាល័យរបស់អង្គការលីកាដូ និងសមត្ថភាពរបស់អង្គការក្នុងការឃ្លាំមើលករណីថ្មីៗផងដែរ ។

ករណីទាំងអស់ដែលបានចងក្រងជាឯកសារនៅក្នុងរបាយការណ៍នេះត្រូវបានឃ្លាំមើលដោយអង្គការលីកាដូបន្ទាប់ពីស្ត្រីត្រូវបានធ្វើឃាត ។ ការណ៍នេះធ្វើឱ្យខ្វះនូវការយល់ដឹងស៊ីជម្រៅលើបទពិសោធន៍ទស្សនៈ និងឧបសគ្គដែលស្ត្រីទាំងនេះជួបប្រទះមុនពេលពួកគេត្រូវបានសម្លាប់ ។ វិសាលភាពត្រូវបានកម្រិតផងដែរចំពោះតែការសម្លាប់ដែលប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល ។ ការសម្លាប់ដែលប្រព្រឹត្តដោយសមាជិកគ្រួសារផ្សេងទៀតមានភាពត្រួតស៊ីគ្នា ប៉ុន្តែជួបប្រទះបញ្ហាប្រឈមដាច់ដោយឡែកពីគ្នា ដូច្នេះវាទាមទារការវិភាគដាច់ដោយឡែក និងមិនត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍នេះទេ ។

[៦] ឃាតកម្មកើតឡើងនៅបាត់ដំបង (១ករណី) កំពង់ចាម (១ករណី) កំពង់ឆ្នាំង (២ករណី) កំពង់ស្ពឺ (២ករណី) កំពង់ធំ (៣ករណី) កណ្ដាល (១ករណី) រាជធានីភ្នំពេញ (៤ករណី) ព្រះសីហនុ (២ករណី) ពោធិ៍សាត់ (១ករណី) សៀមរាប (៥ករណី) ស្វាយរៀង (២ករណី) តាកែវ (១ករណី) និងត្បូងឃ្មុំ (១ករណី) ។

# ការរកឃើញ

## សេចក្តីសង្ខេបនៃករណី

អង្គការលីកាដូ ទទួលបានការរាយការណ៍អំពីករណីអំពើហិង្សាក្នុងគ្រួសារចំនួន ១៧៣ករណី នៅចន្លោះពីខែមករា ឆ្នាំ២០២០ ដល់ខែមិថុនា ឆ្នាំ២០២២ ។ ក្នុងនោះមានករណីចំនួន២៦ ដែលជាប់ពាក់ព័ន្ធនឹងការសម្លាប់ស្ត្រីដោយដៃគូស្និទ្ធស្នាលរបស់នាង រួមមានស្វាមី (១៦ករណី) ដៃគូស្និទ្ធស្នាល (៥ករណី) អតីតស្វាមី (២ករណី) ឬអតីតដៃគូស្និទ្ធស្នាល (៣ករណី) ។[៧] ស្ត្រី ២៦នាក់ កុមារ ៥នាក់ និងបុរសម្នាក់បានស្លាប់ក្នុងករណីទាំងនេះ ។ ស្ត្រីទាំងនេះមានអាយុចាប់ពី២០ ដល់ ៥៧ឆ្នាំ នៅពេលពួកគេត្រូវបានដៃគូសម្លាប់ ហើយច្រើនជាងពាក់កណ្តាលនៃជនរងគ្រោះទាំងនោះ មានអាយុជាង ៣០ឆ្នាំ ។ កុមារ ៥នាក់ ដែលស្លាប់នោះគឺជាក្មេងប្រុស ដែលមានអាយុចន្លោះពី៣ ដល់ ១១ឆ្នាំ ហើយបុរសម្នាក់ ដែលស្លាប់ គឺជាសាច់ញាតិរបស់ជនល្មើសមានអាយុ ៥០ឆ្នាំ ។ កុមារយ៉ាងតិចណាស់ ៨នាក់ ផ្សេងទៀត បានឃើញការសម្លាប់ដោយផ្ទាល់ភ្នែករបស់ពួកគេ ។

អង្គការលីកាដូ បានកត់ត្រាទុកអំពីការកើនឡើងនៃការសម្លាប់ដោយដៃគូស្និទ្ធស្នាល ។ អ្នកឃ្លាំមើលបានចងក្រងករណីឃាតកម្មលើស្ត្រី ៦នាក់ និងកុមារម្នាក់ ក្នុងឆ្នាំ២០២០ ហើយក្នុងឆ្នាំ២០២១ បានចងក្រងករណីឃាតកម្មលើស្ត្រី ១៣នាក់ និងកុមារ ៤នាក់ រីឯនៅក្នុងរយៈពេល ៦ខែដំបូងនៃឆ្នាំ២០២២ បានចងក្រងករណីឃាតកម្មលើស្ត្រី ៧នាក់ ។[៨] ដោយហួសពីវិសាលភាពនៃរបាយការណ៍នេះ អង្គការលីកាដូក៏បានចងក្រងជាឯកសារអំពីករណីឃាតកម្មលើស្ត្រី ១១នាក់ ដោយដៃគូស្និទ្ធស្នាលក្នុងរយៈពេលពេញមួយឆ្នាំ២០២២ ផងដែរ ។ ទោះបីជាចំនួនករណីដែលបានចងក្រង ជាផ្នែកមួយនៃការឆ្លុះបញ្ចាំងពីសមត្ថភាពរបស់លីកាដូនៅក្នុងការទទួលការរាយការណ៍ពីករណីថ្មីក៏ដោយ វាក៏បង្ហាញពីទំនោរដែលស្ត្រីកំពុងប្រឈមមុខនឹងអំពើហិង្សាកាន់តែធ្ងន់ធ្ងរផងដែរ ។

អង្គការលីកាដូ ទទួលបានការរាយការណ៍ពីករណី ដែលស្ត្រីនិងកុមារដែលត្រូវបានសម្លាប់ដោយដៃគូស្និទ្ធស្នាល ឈានដល់កម្រិតខ្ពស់បំផុតក្នុងឆ្នាំ២០២១ ជាឆ្នាំដែលកម្ពុជាបានអនុវត្តវិធានការការពារជំងឺកូវីដ-១៩ យ៉ាងរឹតត្បិតបំផុត ។ រាជរដ្ឋាភិបាលមិនបានផ្សព្វផ្សាយព័ត៌មានទូលំទូលាយអំពីចំនួនករណីអំពើហិង្សាក្នុងគ្រួសារដែលត្រូវបានរាយការណ៍ទៅអាជ្ញាធរ ចំណាត់ការរបស់អាជ្ញាធរ ឬលទ្ធផលនៃសកម្មភាពរបស់ពួកគេនោះទេ ។ ការស្ទង់មតិថ្នាក់ជាតិមានតិចតួច ដែលធ្វើឱ្យមានការពិបាក ក្នុងការវាយតម្លៃការផ្លាស់ប្តូរនៃការរីករាលដាលនៃអំពើហិង្សាក្នុងគ្រួសារ ក្នុងការវាស់វែងពីផលប៉ះពាល់នៃគោលនយោបាយជាតិណាមួយ ឬក្នុងការកំណត់ថាតើកម្ពុជាមាន "ជំងឺរាតត្បាតជាស្រមោល" នៃអំពើហិង្សាស្របពេលនឹងការរាតត្បាតនៃជំងឺកូវីដ-១៩ ដែរឬទេ ។ ទោះជាយ៉ាងណាក៏ដោយវាអាចទៅរួចដែលថាវិធានការរឹតត្បិតដើម្បីទប់ស្កាត់នឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ដូចជាការបិទខ្ទប់យ៉ាងតឹងរ៉ឹង និងការកាត់បន្ថយសេវាសំខាន់ៗមួយចំនួនរបស់អ្នកផ្តល់សេវាកម្មផ្សេងៗ និងតុលាការ បានធ្វើឱ្យអំពើហិង្សានៅក្នុងគ្រួសារកាន់តែធ្ងន់ធ្ងរឡើង ធ្វើឱ្យប៉ះពាល់ដល់សេរីភាពនៃការផ្លាស់ទី និងស្វ័យភាពហិរញ្ញវត្ថុរបស់ស្ត្រី ហើយនិងរារាំងពួកគេមិនឱ្យរាយការណ៍ពីអំពើហិង្សា ។

**ចំនួនស្ត្រី និងកុមារ ដែលត្រូវបានសម្លាប់ដោយដៃគូស្និទ្ធស្នាល**
**(ករណីចងក្រងដោយអង្គការលីកាដូចន្លោះ ឆ្នាំ២០២០ ដល់ ឆ្នាំ២០២២)**




[៧] ករណីអំពើហិង្សាក្នុងគ្រួសារ ៤ករណីបន្ថែមទៀត បណ្តាលឱ្យមានការសម្លាប់ស្ត្រីដោយសាច់ញាតិផ្សេងទៀត រួមមានដោយកូនប្រុស (២ករណី) ក្មួយប្រុស (១ករណី) និងបងប្រុស (១ករណី) ។

[៨] នៅមុនវិសាលភាពនៃរបាយការណ៍នេះ អង្គការលីកាដូបានចងក្រងករណីនៃអំពើឃាតកម្មដោយដៃគូស្និទ្ធស្នាលមកលើស្ត្រី ១២នាក់ និងកូនរបស់ពួកគេ ៣នាក់ ក្នុងឆ្នាំ២០១៨ និង ឃាតកម្មលើស្ត្រី ៩នាក់ ក្នុងឆ្នាំ២០១៩ ។

## ការទទួលបានយុត្តិធម៌មិនដូចគ្នា សូម្បីតែចំពោះអំពើឃាតកម្ម

លទ្ធផល និងនីតិវិធីផ្លូវច្បាប់ដែលមិនស៊ីចង្វាក់គ្នា នៃករណី ដែលត្រូវបានចងក្រងនៅក្នុងរបាយការណ៍នេះ បង្ហាញពីភាពបរាជ័យក្នុងការផ្តល់យុត្តិធម៌ ការផ្តន្ទាទោសឱ្យបានសមស្រប ឬការធ្វើការស៊ើបអង្កេតឱ្យបានទាន់ពេលវេលា នៅគ្រប់ករណីនៃអំពើហិង្សាក្នុងគ្រួសារ ។

គិតត្រឹមខែមករា ឆ្នាំ២០២៣នេះ ជនល្មើសត្រូវបានចាប់ខ្លួន និងផ្តន្ទាទោសចំនួន ១៧ករណី ស្មើ៦៥%នៃករណីទាំង២៦ ។ យ៉ាងតិចណាស់ ៤ករណីនៃករណីទាំងនោះ ស្ថិតក្នុងដំណាក់កាលបណ្តឹងឧទ្ធរណ៍ ខណៈដែល ១ករណីផ្សេងទៀតមិនទាន់បានឈានដល់សាលក្រមស្ថាពរនោះទេ បន្ទាប់ពីជនសង្ស័យត្រូវបានកាត់ទោសដោយកំបាំងមុខ ។

**៦៥%**

នៃករណីដែលត្រូវបានផ្តន្ទាទោស
គិតត្រឹមខែមករា ឆ្នាំ២០២៣

### ស្ថានភាពផ្លូវច្បាប់ នៃករណីទាំង ២៦៖




**ការផ្តន្ទាទោសលើបទឃាតកម្ម៖** ចំនួន ១៤ករណី ក្នុងចំណោម ១៧ករណី មានការផ្តន្ទាទោសជនល្មើសឱ្យជាប់ពន្ធនាគារយ៉ាងតិច ១០ឆ្នាំ ដែលជាការផ្តន្ទាទោសអប្បបរមាសម្រាប់បទឃាតកម្មដោយយោងតាមក្រមព្រហ្មទណ្ឌ ។[៩] ការផ្តន្ទាទោស ៤ករណី ក្នុងចំណោមករណីខាងលើនេះ ជនល្មើសត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត ។ ការផ្តន្ទាទោស ១០ករណី ផ្សេងទៀត ជនល្មើសត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេលពី ១០ ដល់ ១៥ឆ្នាំ ។

---

[៩] មាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ

**ការផ្តន្ទាទោសដោយចោទប្រកាន់ពីបទល្មើសស្រាល និងការដាក់ឱ្យជាប់ពន្ធនាគាររយៈពេលខ្លី៖** ជនល្មើស ៣នាក់ ដែលនៅសល់ត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេលពី ៣ឆ្នាំ ទៅ ៧ឆ្នាំ ។ ក្នុងករណីបែបនេះ ជនល្មើសត្រូវបានចោទប្រកាន់ពីបទឃាតកម្មដោយចេតនា[១០] តាមមាត្រា ២០៧ នៃក្រមព្រហ្មទណ្ឌ ។ ទោះជាស្ត្រីរងគ្រោះធ្លាប់ស្នើសុំជំនួយពីមុនមកហើយនគរបាលនិងអាជ្ញាធរឃុំដឹងអំពីប្រវត្តិដ៏យូរអង្វែងនៃអំពើរំលោភបំពានលើរាងកាយយ៉ាងធ្ងន់ធ្ងរមកលើនាងក៏ដោយ ក៏ជនល្មើសត្រូវបានតុលាការកាត់ទោសជាប់ពន្ធនាគាររយៈពេលត្រឹមតែ ៣ឆ្នាំ ប៉ុណ្ណោះ ។ ព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍លើសាលក្រមនេះ ។ ក្នុងករណីមួយផ្សេងទៀត ជនល្មើស ដែលជាមន្ត្រីនគរបាលខេត្ត ដំបូងឡើយត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល ១១ឆ្នាំ ពីបទឃាតកម្មលើសង្សាររបស់ខ្លួន ។ ព័ត៌មានដែលមាន បង្ហាញថាទោសរបស់ជននោះត្រូវបានកាត់បន្ថយមកត្រឹម ៧ឆ្នាំ ដោយបណ្តឹងឧទ្ធរណ៍ ។ ករណីចុងក្រោយ ជនល្មើសត្រូវបានកាត់ទោសពីបទឃាតកម្ម ។ ដោយសារហេតុផលដែលអង្គការលីកាដូមិនអាចដឹងបាន ជនល្មើសត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេលត្រឹមតែ ៧ឆ្នាំ ប៉ុណ្ណោះ ។

**គ្មានការផ្តន្ទាទោស៖** ក្នុងចំណោមករណីទាំង៩ ដែលមិនមានការផ្តន្ទាទោស ជនសង្ស័យ ២នាក់ ត្រូវបានឃុំឃាំងបណ្តោះអាសន្នរង់ចាំសវនាការ គិតត្រឹមខែមករា ឆ្នាំ២០២៣។ ជនសង្ស័យ ៣នាក់ ផ្សេងទៀត មានដីកាចាប់ខ្លួន ប៉ុន្តែមិនត្រូវបានចាប់ខ្លួននោះទេ ។ ករណី ២ ក្នុងចំណោមករណីទាំងនេះ នគរបាលមិនបានចាត់វិធានការរហូតដល់ព្រឹកឡើងអំពើឃាតកម្មបានកើតមានឡើង ដែលនេះផ្តល់ឱកាសឱ្យជនសង្ស័យរត់គេចខ្លួនទាំងយប់ ។ ជនសង្ស័យ ២នាក់ ផ្សេងទៀតបានស្លាប់ដោយអំពើអត្តឃាតបន្ទាប់ពីសម្លាប់ដៃគូរបស់ខ្លួនរួចហើយ ។ ជនសង្ស័យ ២នាក់ ផ្សេងទៀត ដែលនៅសល់បានស្លាប់នៅក្នុងមន្ទីរឃុំឃាំង ។ ក្នុងករណីមួយ ជនសង្ស័យបានស្លាប់ ដោយសារការសង្ស័យថាត្រូវបានធ្វើទារុណកម្មដោយអាជ្ញាធរ ។ ម្យ៉ាងវិញទៀត អាជ្ញាធរដូចជាមិនបានផ្តល់ជំនួយផ្នែកវេជ្ជសាស្ត្រសមស្របដល់ជនសង្ស័យ ដែលបានស្លាប់នៅក្នុងមន្ទីរឃុំឃាំងនៅព្រឹកបន្ទាប់ ដោយសាររងរបួសពីអំពើហិង្សាដោយហ្វូងមនុស្សក្នុងអំឡុងពេលចាប់ខ្លួន ។[១១] ករណីទាំង ២ នេះឆ្លុះបញ្ចាំងពីភាពបរាជ័យរបស់អាជ្ញាធរក្នុងការការពារអាយុជីវិតរបស់ជនសង្ស័យនៅក្នុងមន្ទីរឃុំឃាំង បន្ថែមលើការបរាជ័យក្នុងការធានាយុត្តិធម៌សម្រាប់ស្ត្រីរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេដែលនៅរស់ ។

## *ជនល្មើសរត់គេចខ្លួនបន្ទាប់ពីមានអំពើហិង្សាកាន់តែធ្ងន់ធ្ងរ*

*សុភា* អាយុជាង ៤០ឆ្នាំ ត្រូវបានសម្លាប់ បន្ទាប់ពីរស់នៅក្នុងចំណងអាពាហ៍ពិពាហ៍ដ៏ហិង្សាអស់រយៈពេលប្រហែល ១៥ឆ្នាំ ។ អតីតស្វាមីរបស់សុភាបានជះទឹកអាស៊ីតទៅលើនាងនិងកូនប្រុស បន្ទាប់ពីសុភាព្យាយាមបញ្ចប់ចំណងអាពាហ៍ពិពាហ៍ម្តងហើយម្តងទៀត ។ កូនប្រុសរបស់នាងបានរួចជីវិតពីការវាយប្រហារប៉ុន្តែរងរបួសធ្ងន់ ។*

*សុភាមានលិខិតព្រមព្រៀងលែងលះ ចំនួន ២ ផ្សេងគ្នាពីអាជ្ញាធរឃុំចំពោះអាពាហ៍ពិពាហ៍ដែលមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍[១២] ប៉ុន្តែនាងមិនទទួលបានការការពារណាមួយពីអាជ្ញាធរទេទោះបីពួកគេដឹងពីអំពើហិង្សាដែលកើតមានជាបន្តបន្ទាប់ក៏ដោយ ។ ឪពុកម្តាយក្មេករបស់សុភាក៏បានព្យាយាមផ្សះផ្សាទំនាក់ទំនងរបស់នាងជាមួយជនល្មើសដែរមុននាងត្រូវអតីតស្វាមីសម្លាប់ ។*

*ម្តាយរបស់សុភាបានលើកឡើងថា ការព្យាយាមលែងលះរបស់សុភានាំឱ្យមានអំពើហិង្សាកាន់តែខ្លាំង ។ ម្តាយរបស់សុភាបាននិយាយថា "ក្រោយផ្តិតមេដៃ (លែងលះ) ចុងក្រោយ វាចេះតែមកកូរពាល់យប់..វាមកអង្វរប្រពន្ធឲ្យទៅវិញ ។ ជនល្មើសបានគំរាម និងប៉ុនប៉ងសម្លាប់នាងជាច្រើនលើកច្រើនសារ រហូតដល់មានម្តងនោះ ឈានដល់ការបញ្ជូននាងទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ ។"*

*ម្តាយរបស់នាងបានបញ្ជាក់ថា អ្នករាល់គ្នាបានដឹងអំពីអំពើហិង្សាធ្ងន់ធ្ងរនិងញឹកញាប់នេះ ។ "អ្នកភូមិគេដឹងទាំងអស់គ្នា ព្រោះអីបើយប់វា(ជនសង្ស័យ)និយាយលឺ ហើយយើងផ្តិតមេដៃលែងលះ ក៏មិនមែនត្រឹមភូមិទេ ឃុំ... (មេភូមិ/មេឃុំ) ដឹងតើ គេដឹង។" ទោះបីកិច្ចអន្តរាគមន៍គឺតម្រូវឲ្យមានដោយច្បាប់ ទោះបីជាមានឬគ្មានពាក្យបណ្តឹងពីជនរងគ្រោះក៏ដោយ[១៣] ប៉ុន្តែអាជ្ញាធរមូលដ្ឋានមិនបានធ្វើអន្តរាគមន៍ ឬបង្វែរករណីនេះទៅជានីតិវិធីព្រហ្មទណ្ឌនោះទេ ។*

*អាជ្ញាធរមិនព្រមនាំខ្លួនជនល្មើសមកទទួលខុសត្រូវទេ ទោះបីជាបន្ទាប់ពីជនល្មើសបានវាយប្រហារសុភានិងកូនរបស់នាងដោយទឹកអាស៊ីតក៏ដោយ ។ ម្តាយនាងបាននិយាយថា "ខ្ញុំរត់ទៅហៅមេភូមិ ឲ្យមកជួយតេហៅប៉ូលីស ។" "គាត់ចុចទូរស័ព្ទ ចុចទៅគេអត់លើក គាត់ថាអត់ចូល គាត់អត់មានរាយការណ៍ថាឯងគ្រោះថ្នាក់អញ្ចឹង ។"*

*ការខកខានរបស់អាជ្ញាធរក្នុងការធ្វើអន្តរាគមន៍បានធ្វើឱ្យជនល្មើសគេចពីការចាប់ខ្លួន ។ "[មេភូមិ/មេឃុំ/សន្តិសុខភូមិ] អត់មានអន្តរាគមន៍ម៉េចៗ គេអត់មកហ្នឹង ។" "ជនរងគ្រោះ(កូនខ្ញុំ)គ្នាគ្រោះថ្នាក់ដល់ស្លាប់ហើយ ឯង(ជនសង្ស័យ)នៅសប្បាយ អត់ធ្វើអីគេកើត ។"*

**ឈ្មោះត្រូវបានផ្លាស់ប្តូរ*

[១០] ឃាតកម្មដោយអចេតនា រួមទាំងការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការប្រតិបត្តិដែលធ្វេសប្រហែស ។

[១១] ការវាយប្រហារដោយហ្វូងមនុស្សត្រូវបានចងក្រងជាឯកសារយ៉ាងត្រឹមត្រូវនៅក្នុងប្រទេសកម្ពុជា ហើយជារឿយៗត្រូវបានបញ្ឆេះដោយភាពខ្វះទំនុកចិត្តលើនីតិរដ្ឋ ។ សូមមើល "តុលាការប្រជាជន ការការពារនិងការឆ្លើយតបចំពោះ "យុត្តិធម៌ដ៏ពេញនិយម" ក្នុងប្រទេសកម្ពុជា" OHCHR ឆ្នាំ២០១៩ ដកស្រង់ពី៖ https://cambodia.ohchr.org/sites/default/files/report/other-report/OHCHR%20Report% 20EN.pdf

[១២] សម្រាប់ការពិភាក្សាអំពីការរៀបការដែលមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ សូមមើលទំព័រ១០ និង ១១ ។

[១៣] មាត្រា៩ នៃច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ (ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ) មាត្រា៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## អំពើហិង្សាដែលបង្កឡើងដោយបទដ្ឋានយេនឌ័រ និងវប្បធម៌នៃការគ្រប់គ្រង

បទដ្ឋានយេនឌ័រនៅកម្ពុជាបន្តជំរុញឱ្យមានអំពើហិង្សាក្នុងគ្រួសារ និងធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពរបស់ស្ត្រីក្នុងការស្វែងរកនិងទទួលជំនួយ ។ បុគ្គលនិងស្ថាប័នជាច្រើននៅតែផ្តល់តម្លៃដល់ស្ត្រីដោយផ្អែកលើសមត្ថភាពនិងឆន្ទៈរបស់នាងក្នុងការបម្រើដៃគូរបស់ពួកគេ និងថែរក្សាចំណងគ្រួសារ ឬភាពសុខដុមរមនានៃគ្រួសារ ទោះបីជានៅពេលប្រឈមនឹងអំពើហិង្សាធ្ងន់ធ្ងរក៏ដោយ ។ ការមិនទទួលយកបទដ្ឋានយេនឌ័រ ជាញឹកញាប់ត្រូវបានគេយល់ឃើញ អំពើនេះសមនឹងទទួលរងនូវអំពើហិង្សា ។[14]

ក្នុងចំណោម ២៦ករណី ស្ត្រីជាច្រើនប្រឈមមុខនឹងអំពើហិង្សាដែលជំរុញដោយបទដ្ឋានយេនឌ័រនិងដោយការព្យាយាមរបស់ដៃគូដើម្បីបង្ហាញពីការគ្រប់គ្រងយ៉ាងខ្លាំងមកលើជីវិតរបស់ស្ត្រីទាំងនោះ។

ការឃ្លាំមើលរបស់អង្គការរលីកាដូបានបញ្ជាក់ថាយ៉ាងតិចណាស់មាន ២៣ករណី ក្នុងចំណោម ២៦ករណី ដែលមានភ័ស្តុតាងនៃជម្លោះពាក្យសម្តីបន្តបន្ទាប់នៅក្នុងទំនាក់ទំនង ។ អំពើហិង្សាឬភាពតានតឹងផ្ទុះឡើងដោយសារភាពប្រច័ណ្ឌរបស់ជនល្មើសនៅក្នុងករណីយ៉ាងតិចណាស់ចំនួន ១៤ ក្រោយពេលដែលស្ត្រីជាច្រើនត្រូវបានចោទប្រកាន់ដោយដៃគូថាបាន៖

- ប្រើភាសាហាក់ដូចជាមិនសមរម្យ
- និយាយជាមួយមិត្តភក្តិតាមប្រព័ន្ធអនឡាញ
- មិនរួមភេទ
- មិនលក់ទ្រព្យសម្បត្តិរួម
- ជំពាក់បំណុលមីក្រូហិរញ្ញវត្ថុ
- តុបតែងមុខនិងលក់គ្រឿងសម្អាង
- ចូលរួមកម្មវិធីជប់លៀង និងផឹកស្រាជាមួយមិត្តភក្តិ និង/ឬ
- លេងហ្គេម និងលេងបៀ ដោយមិនធ្វើការងារផ្ទះ ។

ការស្ទង់មតិមួយចំនួនដែលបានធ្វើឡើងនៅចន្លោះ ឆ្នាំ២០០៩ និងឆ្នាំ២០១៥ បានបង្ហាញពីវិសាលភាពនៃអំពើហិង្សាក្នុងគ្រួសារដែលត្រូវបានលើកលែងទោសនៅក្នុងប្រទេសកម្ពុជា ។ ក្នុងនោះ ស្ត្រីចំនួនជិតពាក់កណ្តាលដែលបានស្ទង់មតិបានរាយការណ៍ថា ពួកគេជឿថាអំពើហិង្សាផ្លូវកាយគឺសមហេតុផលក្នុងកាលៈទេសៈមួយចំនួន[15] ដែលពីរភាគបី (២/៣) នៃស្ត្រីទាំងនោះរាយការណ៍ថាពួកគេជឿថាស្ត្រីគួរតែអត់ធន់ចំពោះអំពើហិង្សា ដើម្បីរក្សាគ្រួសារឱ្យរស់នៅជាមួយគ្នា[16] និងជាងមួយភាគបី (១/៣) នៃអាជ្ញាធរមូលដ្ឋានដែលបានស្ទង់មតិរាយការណ៍ថាអំពើហិង្សាធ្ងន់ធ្ងរគឺសមហេតុផល ប្រសិនបើស្ត្រីមិនស្តាប់បង្គាប់ ឬមិនគោរពស្វាមីរបស់ពួកគេនោះទេ ។[17]

[14] ការស្ទង់មតិជាតិស្តីពីសុខភាពស្ត្រីនិងបទពិសោធន៍ជីវិតនៅកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា ទំព័រ៦៥-៦៦

[15] ប្រភពដូចយោងខាងលើ

[16] Emma Fulu, et al, "ហេតុអ្វីបានជាបុរសខ្លះប្រើអំពើហិង្សាលើស្ត្រី ហើយតើយើងអាចការពារដោយរបៀបណា?" ទំព័រ៥៣ ឆ្នាំ២០១៣ ដកស្រង់ពី៖http://www.partners4prevention.org/sites/default/files/resources/p4p-report.pdf

[17] "អំពើហិង្សាលើស្ត្រី៖ ការស្ទង់មតិតាមដានឆ្នាំ២០០៩" ក្រសួងកិច្ចការនារី (កកន) ទំព័រ៧៤ ដកស្រង់ពី៖https://www.undp.org/sites/g/files/zskgke326/files/migration/kh/Violence_Against_Women_2009_Follow-Up_Survey_Full_Report_Eng.pdf

## បទដ្ឋានយេនឌ័រនិងស្វ័យភាពផ្លូវភេទ

ស្រីលាភ* មានអាយុជាង ៣០ឆ្នាំ ត្រូវបានអតីតដៃគូសម្លាប់នៅចំពោះមុខកូនស្រីរបស់នាង បន្ទាប់ពីជននោះព្យាយាមគ្រប់គ្រងនាងយ៉ាងខ្លាំង ។ ជនល្មើសបានចាប់ផ្តើមដាក់សម្ពាធមកលើស្រីលាភឱ្យរស់នៅជាមួយគាត់ ។ ជនល្មើសបានសង់សឹក នៅពេលដែលនាងបានសម្រេចចិត្តរស់នៅម្នាក់ឯង និងបញ្ចប់ទំនាក់ទំនង ។ ប្អូនស្រីរបស់ស្រីលាភបាននិយាយថា "ពេលហ្នឹងវា(ជនសង្ស័យ)ឃាត់អត់ឲ្យទៅការគេ តែប្អូនខ្ញុំវាចង់ទៅការគេ ដល់ពេលអញ្ចឹងទៅ វាថាបើទៅការគេ យប់នឹងវាមកសុំដេកជាមួយ បើអត់ឲ្យវាដេកជាមួយ វាសម្លាប់ចោលហើយ" ដោយបានលើកឡើងពីការប៉ុនប៉ងរបស់ជនល្មើសនៅក្នុងការគ្រប់គ្រងស្វ័យភាពផ្លូវភេទរបស់នាង ។ "អាហ្នឹង(ជនសង្ស័យ) វាសុំដេកជាមួយ តែអត់ឲ្យដេកជាមួយ វាថាយប់ហ្នឹងវាមកសម្លាប់ហើយ ។" ក្រោយមកគាត់ត្រូវបានចាប់ខ្លួន និងផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ ១២ឆ្នាំ ។

## អំពើហិង្សា និងការគ្រប់គ្រងផ្នែកសេដ្ឋកិច្ច

សម្ផស្ស* មានអាយុជាង ៤០ឆ្នាំ ត្រូវបានប្តីសម្លាប់នៅមុខកូនៗរបស់នាង ។ ជនល្មើសធ្លាប់មានរបួសក្បាលច្រើនឆ្នាំមកហើយ ដែលគ្រួសាររបស់សម្ផស្សជឿថាជាមូលហេតុនៃការផ្លាស់ប្តូរអាកប្បកិរិយារបស់គាត់មុនប្រព្រឹត្តិអំពើឃាតកម្ម ។ សម្ផស្សត្រូវបានជនល្មើសគ្រប់គ្រងលើអាកប្បកិរិយាជិត ២ទសវត្សរ៍ នៃជីវិតអាពាហ៍ពិពាហ៍របស់ពួកគេ ។ ការសម្រេចចិត្ត ផ្នែកសេដ្ឋកិច្ចរបស់សម្ផ័ស្សនៅក្នុងគ្រួសារ ត្រូវបានកម្រិត ហើយការចំណាយរបស់នាងត្រូវបានគ្រប់គ្រងយ៉ាងតឹងរ៉ឹងដោយស្វាមីរបស់នាង៖ "ចង់ទិញអីក៏ដោយ ប្តីមិនឲ្យទិញមិនឲ្យធ្វើ ។" "អត់មានថាវ៉ៃអីទេ គ្រាន់តែជជែកគ្នាតិចតួចអីមិនដែលអត់ទេ ប្តីប្រពន្ធ... ប៉ុន្តែគ្រាន់តែវាទុកលាក់ក្នុងចិត្តវា ។" បងស្រីរបស់សម្ផស្សនិយាយថា នៅពេលជំងឺរាតត្បាតបានកាត់បន្ថយប្រាក់ចំណូលរបស់សម្ផស្ស នាងបានសម្រេចចិត្តលក់ផលិតផលគ្រឿងសម្អាងតាមអនឡាញ ។ ប្តីរបស់នាងខឹងនឹងនាងចំពោះការប្រើប្រាស់ផលិតផលដោយខ្លួនឯង និងការផ្លាស់ប្តូរការតែងខ្លួនរបស់នាង ហើយទាមទារឱ្យនាងឈប់តុបតែងខ្លួននិងបញ្ឈប់សកម្មភាពរកស៊ីដែលបានជួយទ្រទ្រង់ជីវភាពរបស់នាងអំឡុងពេលមានជំងឺកូវីដរាតត្បាត ។ "ឯងអើយឯង វិលទៅពីមុនវិញទៅ កុំធ្វើខ្លួនធ្វើអី ទុកលុយទុកកាក់អាទិញម្សៅលាប ទុកលុយទិញអីផ្សេង [ទិញម្ហូប ទិញបង្អែមនំឲ្យកូន] ។" ប៉ុន្មានខែក្រោយមក ជននោះបានសម្លាប់នាង ។ ក្រោយមក ជនល្មើសបានសម្លាប់ខ្លួនឯង ។

*ឈ្មោះត្រូវបានផ្លាស់ប្តូរ

## បញ្ហាប្រឈមក្នុងការរាយការណ៍អំពីអំពើហិង្សា

ឧបសគ្គដែលស្រ្តីជួបប្រទះក្នុងការស្វែងរកការគាំទ្រ និងយុត្តិធម៌ចំពោះអំពើហិង្សាក្នុងគ្រួសារ ត្រូវបានគេបានដឹងយ៉ាងច្បាស់ ។[១៨] ក្រសួងកិច្ចការនារី (កកន) ខ្លួនឯងក៏បានទទួលស្គាល់ថា "មានស្រ្តីតិចតួចប៉ុណ្ណោះដែលកំពុងស្វែងរកជំនួយពីសេវាសាធារណៈផ្លូវការដូចជានគរបាល អ្នកផ្តល់សេវាសុខាភិបាល និងអ្នកប្រឹក្សាយោបល់ ។"[១៩] នៅក្នុងការស្ទង់មតិថ្នាក់ជាតិ ឆ្នាំ២០១៥ ស្ទើរតែពាក់កណ្តាលនៃស្រ្តីដែលបានជួបប្រទះអំពើហិង្សាក្នុងគ្រួសារ បានរាយការណ៍ថាមិនដែលប្រាប់នរណាម្នាក់អំពីអំពើហិង្សានោះឡើយ ។[២០] តម្លៃដែលបានផ្តល់ទៅលើចំណងអាពាហ៍ពិពាហ៍ថាជាផ្នែកដ៏សំខាន់មួយនៃការរស់នៅក្នុងសហគមន៍ ហើយសម្ពាធគ្រួសារនិងសង្គមឱ្យរក្សាចំណងអាពាហ៍ពិពាហ៍ឱ្យបានគង់វង្ស ជារឿយៗរារាំងស្ត្រីពីការនិយាយជាសាធារណៈអំពីអំពើហិង្សាក្នុងគ្រួសារ ។ ការពង្រឹងបទដ្ឋានយេនឌ័រ ការភ័យខ្លាចចំពោះការសងសឹក និងការមិនទុកចិត្តលើអាជ្ញាធរ អាចរារាំងស្ត្រីពីការរាយការណ៍ពីអំពើហិង្សា និងស្វែងរកការលែងលះ ។ ស្ត្រីដែលពឹងផ្អែកផ្នែកហិរញ្ញវត្ថុលើជនល្មើស មិនអាចមានលទ្ធភាពរស់នៅបែកគ្នា ឬឱ្យជនល្មើសជាប់គុកបាននោះទេ ហើយកាន់តែទទួលរងសម្ពាធកាន់តែធ្ងន់ឱ្យអត់ធ្មត់ និងស្ងៀមស្ងាត់ពេលមានអំពើហិង្សា ។

ការស្រាវជ្រាវរបស់អង្គការលីកាដូបញ្ជាក់ថា យ៉ាងតិចណាស់ស្ត្រី ១៦នាក់ ត្រូវបានសម្លាប់បន្ទាប់ពីមានការប៉ុនប៉ងរបស់ដៃគូជាច្រើនដងពីមុនមក ដើម្បីគ្រប់គ្រងលើនាងតាមរយៈអំពើហិង្សាផ្លូវកាយ សេដ្ឋកិច្ច ឬផ្លូវភេទ ឬទង្វើនៃការគំរាមកំហែងផ្សេងទៀត ។ ដោយគិតទៅលើបញ្ហាដែលស្ត្រីជាច្រើនមិនដែលទុកចិត្តក្នុងការនិយាយប្រាប់នរណាម្នាក់អំពីអំពើហិង្សា ក្នុងតថភាពជាក់ស្តែងតួលេខខាងក្រោមអាចនឹងខ្ពស់ជាងនេះ ។ ក្នុងចំណោម ២៦ករណី មាន៖

- យ៉ាងតិចណាស់ស្ត្រី ១២នាក់ ធ្លាប់ជួបប្រទះអំពើហិង្សាផ្លូវកាយពីមុន ។
- យ៉ាងតិចណាស់ស្ត្រី ២នាក់ ធ្លាប់ជួបប្រទះអំពើហិង្សាផ្នែកសេដ្ឋកិច្ចពីមុន ។
- យ៉ាងតិចណាស់ស្ត្រី ២នាក់ ធ្លាប់ជួបប្រទះអំពើហិង្សាផ្លូវភេទពីមុន ។
- យ៉ាងតិចណាស់ស្ត្រី ១១នាក់ រងគ្រោះពីអាកប្បកិរិយាដែលបញ្ជាក់ពីអំពើហិង្សាផ្លូវចិត្ត ឬអារម្មណ៍ ដូចជាមិនអនុញ្ញាតឱ្យជួបអ្នកដទៃ មិនអនុញ្ញាតឱ្យតុបតែងខ្លួន ការគំរាមកំហែងដល់អាយុជីវិត ការតាមប្រម៉ាញ់ និងការបំភិតបំភ័យដោយការបោក ឬបំផ្លាញសម្ភារៈក្នុងផ្ទះ ។

### ចំនួនស្ត្រីដែលប្រឈមនឹងអំពើហិង្សាក្នុងគ្រួសារមុនពេលស្លាប់




[១៨] សូមមើលការសង្កេតបញ្ចប់លើរបាយការណ៍ទី៦ នៃការត្រួតពិនិត្យឡើងវិញតាមពេលវេលាកំណត់របស់ប្រទេសកម្ពុជា គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី (គណៈកម្មាធិការ CEDAW) CEDAW/C/KHM/CO/6 កថាខណ្ឌទី១០ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដកស្រង់ពី៖ https://tbinternet.ohchr.org/_layouts/15/treatybodyexternal/Download.aspx?symbolno=CEDAW%2FC%2FKHM%2FCO%2F6&Lang=en

[១៩] "បទពិសោធន៍របស់ស្ត្រីអំពីអំពើហិង្សាក្នុងគ្រួសារនិងទម្រង់ផ្សេងទៀតនៃអំពើហិង្សា៖ របាយការណ៍វិភាគទិន្នន័យបន្ទាប់បន្សំរបស់ CDHS ឆ្នាំ២០១៥ កកន ទំព័រ៣៨ ខែតុលា ឆ្នាំ២០១៦ ដកស្រង់ពី៖ https://asiapacific.unfpa.org/sites/default/files/pub-pdf/Cambodia%20CDHS%20VAW%20study%20secondary%20analysis%20DV%2017%20October%202016%20Eng pdf

[២០] ការស្ទង់មតិជាតិស្តីពីសុខភាពស្ត្រីនិងបទពិសោធន៍ជីវិតនៅកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា ទំព័រ៨៨

ទោះបីជាបានជម្នះឧបសគ្គដ៏ធំសម្បើមក្នុងការរាយការណ៍អំពីអំពើហិង្សា ឬស្នើសុំការលែងលះក៏ដោយ ការឆ្លើយតបរបស់អាជ្ញាធរចំពោះសំណើរបស់ស្ត្រីជារឿយៗមិនទាន់គ្រប់គ្រាន់នៅឡើយ ។ ជាញឹកញាប់ អាជ្ញាធរមិនបានធ្វើសកម្មភាពចាត់វិធានការលើអំពើហិង្សាដែលពួកគេបានដឹង ឬនៅក្នុងសហគមន៍របស់ពួកគេនោះទេ ដែលនេះអាចជាកត្តាមួយរួមចំណែកនាំឱ្យចំនួនស្ត្រីតិចតួចប៉ុណ្ណោះ ដែលដាក់ពាក្យបណ្ដឹងទៅនគរបាល ឬស្វែងរកយុត្តិធម៌ផ្នែកព្រហ្មទណ្ឌ ។

ក្រមនីតិវិធីព្រហ្មទណ្ឌ កំណត់ថាអាជ្ញាធរឬមន្ត្រីសាធារណៈទាំងអស់ដែលដឹងអំពីបទមជ្ឈិម ឬបទឧក្រិដ្ឋ មានកាតព្វកិច្ចរាយការណ៍ពីឧប្បត្តិហេតុទៅព្រះរាជអាជ្ញា ឬនគរបាលយុត្តិធម៌ ដែលនេះជាជំហានសំខាន់មួយឆ្ពោះទៅរកការកាត់ក្ដី ។[២១] ច្បាប់ស្ដីពីអំពើហិង្សាក្នុងគ្រួសារ ផ្ដល់អំណាចបន្ថែមដល់អាជ្ញាធរជាច្រើនរួមមានមេភូមិ អាជ្ញាធរឃុំ កងរាជអាវុធហត្ថ និងមន្ត្រីក្រសួងកិច្ចការនារី មានអំណាចដូចគ្នាទៅនឹងនគរបាលយុត្តិធម៌ក្នុងការបញ្ជូនព័ត៌មានអំពីអំពើហិង្សាក្នុងគ្រួសារទៅព្រះរាជអាជ្ញា ។[២២] ទោះជាយ៉ាងនេះក្ដី មិនមានភ័ស្ដុតាងណាមួយ ដែលបញ្ជាក់ថាអាជ្ញាធរបានបំពេញកាតព្វកិច្ចរបស់ខ្លួននៅក្នុងករណីណាមួយដែលលីកាដូបានចងក្រងនោះទេ ។

អាជ្ញាធរមូលដ្ឋានឬនគរបាលបានដឹងពីការព្យាយាមរបស់ស្ត្រីដើម្បីរស់នៅបែកគ្នា ឬអាកប្បកិរិយាហិង្សារបស់ដៃគូស្ត្រីទាំងនោះ យ៉ាងតិចណាស់ក្នុង ១១ ករណី ក្នុងចំណោម ២៦ករណី ។ ក្នុងចំណោមករណីទាំងនេះ៖

- យ៉ាងតិចណាស់ស្ត្រី ៩នាក់ ឬសមាជិកគ្រួសាររបស់ពួកគេបានទាក់ទងផ្ទាល់ជាមួយអាជ្ញាធរដើម្បីប្ដឹង ស្នើសុំជំនួយ និង/ឬ ស្វែងរកការលែងលះមុនការស្លាប់របស់ពួកគេ ។
  - យ៉ាងតិចណាស់ ៥ករណី ស្ត្រីទាំងនោះ គ្រួសារ ឬសហគមន៍របស់ពួកគេបានស្វែងរកជំនួយឬប្ដឹងអំពីអំពើហិង្សា ។ អ្នកទាំងនោះជាញឹកញាប់បានទៅរកមេភូមិឬនគរបាល ។
  - យ៉ាងតិចណាស់ស្ត្រី ៦នាក់ បានទាក់ទងអាជ្ញាធរដើម្បីជួយលើការលែងលះឬចែកផ្លូវគ្នា ។ ពួកគេជាញឹកញាប់ទៅរកអាជ្ញាធរឃុំ ។ ក្នុងករណី ២ ទៀត អាជ្ញាធរភូមិ អាជ្ញាធរឃុំ និងនគរបាលសុទ្ធតែជាប់ពាក់ព័ន្ធនឹងសំណើសុំលែងលះ និងការដាក់ពាក្យលែងលះ ។
- យ៉ាងតិចណាស់ ២ករណីផ្សេងទៀត អាជ្ញាធរបានដឹងពីអំពើហិង្សាដែលកំពុងកើតមានឡើង ឬជនល្មើសមានជាប់ពាក់ព័ន្ធនឹងអាកប្បកិរិយាហិង្សាពីមុនមក ទោះបីជាមិនបានទទួលការស្នើសុំជំនួយដោយផ្ទាល់ពីជនរងគ្រោះក៏ដោយ ។

ការរកឃើញទាំងនេះ គឺផ្អែកលើព័ត៌មានដែលអង្គការលីកាដូទទួលបាន ។ ចំនួនពិតប្រាកដនៃស្ត្រីដែលទាក់ទងជាមួយអាជ្ញាធរអាចខ្ពស់ជាងនេះ ។

## ការដឹងលឺរបស់អាជ្ញាធរចំពោះអំពើហិង្សា ឬការចង់បានរបស់ស្ត្រី ក្នុងការចាកចេញពីទំនាក់ទំនងស្នេហា




[២១] មាត្រា៤២ នៃក្រមព្រហ្មទណ្ឌ

[២២] មាត្រា៩ និង១១ នៃច្បាប់ស្ដីពីអំពើហិង្សាក្នុងគ្រួសារ

## ការព្យាយាមចាកចេញ៖ ឧបសគ្គចំពោះការលែងលះ និងរស់នៅបែកគ្នា

នីតិវិធី ដើម្បីទទួលបានការលែងលះនៅក្នុងប្រទេសកម្ពុជាគឺជាឧបសគ្គចម្បងសម្រាប់ស្ត្រី ដែលស្វែងរកការចាកចេញពីចំណងអាពាហ៍ពិពាហ៍ហិង្សា ។

អាជ្ញាធរឃុំ ត្រូវស្នើសុំសំបុត្រអាពាហ៍ពិពាហ៍ផ្លូវការ ។ ដោយសារប្តីប្រពន្ធជាច្រើនមិនបានដឹងឬជ្រើសរើសមិនមានសំបុត្រអាពាហ៍[២៣] ពិពាហ៍ក្រោយពេលមានពិធីរៀបការ មនុស្សជាច្រើននៅតែបន្តរស់នៅក្នុងការរៀបការដែលមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ដែលត្រូវបានទទួលស្គាល់ដោយសង្គមនិងអាជ្ញាធរមូលដ្ឋាន ប៉ុន្តែមិនត្រូវបានទទួលស្គាល់ដោយច្បាប់ ។ ទាំងស្ត្រីដែលស្ថិតនៅក្នុងការរៀបការដែលបានចុះឬមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ជារឿយៗតែងប្រឈមមុខនឹងបញ្ហាចម្បងៗក្នុងការលែងលះ ទោះបីជាមានភស្តុតាងនៃអំពើហិង្សាធ្ងន់ធ្ងរឬកំពុងកើតឡើងជាបន្តបន្ទាប់ក៏ដោយ ។ ប្តីប្រពន្ធដែលមិនទាន់រៀបការ ជួនកាលក៏ទៅជួបអាជ្ញាធរមូលដ្ឋានដើម្បីស្នើសុំឱ្យជួយក្នុងការសម្របសម្រួលការចែកផ្លូវគ្នា ហើយជួបបញ្ហាប្រឈមស្រដៀងគ្នាដែរ ។

### ទំនាក់ទំនងរបស់ស្ត្រី និងជនល្មើស




ការរៀបការដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ អាចលែងលះដោយតុលាការរដ្ឋប្បវេណី ដែលអាចកំណត់លើការចិញ្ចឹមនិងផ្គត់ផ្គង់កូន សោធនអាហារកិច្ច និងការបែងចែកទ្រព្យសម្បត្តិរួម ។ ដំណើរការលែងលះមានភាពស្មុគស្មាញ ចំណាយប្រាក់ច្រើន ចំណាយពេលវេលាយូរ និងតម្រូវឱ្យមានការធ្វើដំណើរម្តងហើយម្តងទៀតទៅកាន់តុលាការដែលមានទីតាំងក្នុងរាជធានីខេត្ត ។ បទពិសោធន៍របស់អង្គការលីកាដូក្នុងសំណុំរឿងមួយចំនួនដែលមិនបានលើកឡើងនៅក្នុងរបាយការណ៍នេះ បង្ហាញថាស្ត្រីត្រូវធ្វើដំណើរទៅតុលាការរហូតដល់៥ដង ដាច់ដោយឡែកពីគ្នា ដើម្បីទទួលបានការលែងលះ ។ កត្តាទាំងនេះអាចរារាំងដល់លទ្ធភាពនៃការលែងលះ ជាពិសេសចំពោះស្ត្រីក្រីក្រ ដែលពឹងផ្អែកផ្នែកហិរញ្ញវត្ថុលើប្តី រស់នៅតំបន់ដាច់ស្រយាល ឬមានកម្រិតអក្ខរកម្មទាប ។

យ៉ាងតិចណាស់ស្ត្រី ៦នាក់ ក្នុងចំណោម ២៦នាក់ ដែលត្រូវបានសម្លាប់ ធ្លាប់ទៅរកអាជ្ញាធរភូមិឃុំ ដើម្បីស្វែងរកការលែងលះឬចែកផ្លូវគ្នា ។ ក្នុងចំណោមនេះ៖

- ស្ត្រី ៤នាក់ បានរៀបការដោយគ្មានសំបុត្រអាពាហ៍ពិពាហ៍ ។ អាជ្ញាធរឃុំបានចេញកិច្ចព្រមព្រៀងលែងលះក្នុង ២ករណី ដែលនៅក្នុងករណីមួយបានកោះហៅជនល្មើសម្តងហើយម្តងទៀតឱ្យចូលរួមក្នុងដំណើរការលែងលះ ប៉ុន្តែគាត់បានបដិសេធដោយមិនចូលរួម ហើយករណីមួយទៀតបានកោះហៅស្ត្រីម្នាក់មកជួប ប៉ុន្តែនាងត្រូវបានគេសម្លាប់មុនពេលនាងមកជួប ។
- ស្ត្រីម្នាក់មានសំបុត្រអាពាហ៍ពិពាហ៍ ។ អាជ្ញាធរភូមិបានព្យាយាមសម្រុះសម្រួលករណីនេះ និងផ្សះផ្សាដៃគូក្នុង ៣ករណី ។ មិនមានការបញ្ជូនបន្តសម្រាប់ដំណើរការលែងលះរដ្ឋប្បវេណីនោះទេ ។
- ស្ត្រីម្នាក់មិនបានរៀបការ ។ អាជ្ញាធរភូមិ "ណែនាំ" នាង និងព្យាយាមសម្របសម្រួលឱ្យប្តីប្រពន្ធផ្សះផ្សាគ្នាវិញ ។

លទ្ធផលនេះគឺផ្អែកលើព័ត៌មានដែលអង្គការលីកាដូទទួលបាន ។ ចំនួនពិតប្រាកដនៃស្ត្រីដែលព្យាយាមទាក់ទងជាមួយអាជ្ញាធរដើម្បីលែងលះ ឬរស់នៅបែកគ្នា អាចខ្ពស់ជាងនេះ ។

[២៣] ៤៤% នៃស្ត្រីដែលមិនធ្លាប់មានដៃគូនៅក្នុងប្រទេសកម្ពុជាបានរាយការណ៍ថាពួកគេបានរៀបការដោយគ្មានការចុះសំបុត្រអាពាហ៍ពិពាហ៍
សូមមើលការស្ទង់មតិជាតិស្តីពីសុខភាពស្ត្រីនិងបទពិសោធន៍ជីវិតនៅកម្ពុជា ក្រសួងកិច្ចការនារី ទំព័រ៤៤

ទន្ទឹមនេះដែរ មិនមាននីតិវិធីផ្លូវការណាមួយ ដើម្បីរំលាយការរៀបការដែលមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ ។ ជាធម្មតា អាជ្ញាធរឃុំដែលនៅទីលំនៅអចិន្ត្រៃយ៍របស់បុគ្គលនោះ ត្រួតពិនិត្យកិច្ចព្រមព្រៀងលែងលះរវាងភាគីទាំងពីរ ។ ការណ៍នេះធ្វើឱ្យស្ត្រីជាប់អន្ទាក់ក្នុងទំនាក់ទំនងហិង្សា ដោយទាមទារឱ្យដៃគូរំលោភបំពានមានវត្តមានទាំង ២នាក់ និងយល់ព្រមលើការចែកផ្លូវគ្នា ។ ស្ត្រីទាំងនោះនឹងនៅតែជួបហានិភ័យក្នុងការមិនទទួលបានសិទ្ធិក្នុងការរស់នៅដោយគ្មានអំពើហិង្សា រហូតទាល់តែមានគោលនយោបាយ និងនីតិវិធីថ្នាក់ជាតិ ដើម្បីរំលាយការរៀបការដែលមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ដែលមិនតម្រូវឱ្យមានវត្តមាននិងការយល់ព្រមពីជនល្មើស។

**ស្ត្រី ៦នាក់** ធ្លាប់ទៅរកអាជ្ញាធរភូមិឃុំ ដើម្បីស្វែងរកការលែងលះឬចែកផ្លូវគ្នា



**ស្ត្រី ៤នាក់** នៅតែស្ថិតក្នុងទំនាក់ទំនងហិង្សា ដោយសារនីតិវិធីលែងលះមិនយុត្តិធម៌ ឬភាពទន់ខ្សោយនៃការអន្តរាគមន៍

**ស្ត្រី ២នាក់** ប្រឈមនឹងការសងសឹកពីជនល្មើសក្រោយការលែងលះ

## *ការរារាំងពីការលែងលះ*

*ចាន់នី* មានអាយុជាងហាសិបឆ្នាំ ត្រូវបានប្តីរបស់នាងសម្លាប់ នៅពេលនាងកំពុងព្យាយាមលែងលះជាមួយប្តីរបស់នាង ។ គូស្នេហ៍មួយគូនេះមិនមានសំបុត្រអាពាហ៍ពិពាហ៍ទេ ហើយចាន់នីបានស៊ូទ្រាំនឹងការឈ្លោះប្រកែកគ្នាជាច្រើនឆ្នាំក្នុងចំណងអាពាហ៍ពិពាហ៍ដែលនាងមិនស្ម័គ្រចិត្ត ។ ប្អូនស្រីរបស់ចាន់នីបាននិយាយថា "គាត់ការហ្នឹង ដូចថាតាមឪពុកមារ-ម្តាយមីង...គាត់និយាយថាគាត់អត់ចង់ការទេ ។"*

*ជាច្រើនឆ្នាំមុនត្រូវបានសម្លាប់ ចាន់នីបានព្យាយាមសុំសំបុត្រអាពាហ៍ពិពាហ៍ពីអាជ្ញាធរឃុំ ដើម្បីស្នើសុំការលែងលះផ្លូវការមួយ ។ នាងបានធ្វើដំណើរពីទីក្រុងដែលនាងរស់នៅទៅស្រុកកំណើត ដើម្បីស្នើសុំការលែងលះពីអាជ្ញាធរឃុំនៅទីនោះ ។ ខណៈដែលនីតិវិធីដើម្បីទទួលបានការលែងលះ តម្រូវឱ្យមានវត្តមានប្តីរបស់នាង ប៉ុន្តែនៅតែមិនជោគជ័យ ។ ប្អូនស្រីរបស់នាងនិយាយថា "ពេលដែលទៅហ្នឹង គាត់ប្រាប់ខ្ញុំថាគាត់ទៅលែងលះជាមួយប្តីគាត់ហើយ...គាត់ទៅ គាត់ឲ្យប្តីគាត់ទៅជាមួយ ប៉ុន្តែរួចទៅប្តីគាត់ថា ង៉ែងទៅមុនចុះ អញមិនឲ្យជិះឡានអញទេ...មិនឲ្យជិះហីទៅអញជិះតាក់ស៊ីទៅ ហើយឲ្យប្តីគាត់ទៅតាមក្រោយ (ប្តី)អត់ទៅ ។"*

*ចាន់នីបានស្វែងរកការគាំទ្រតិចតួចពីអ្នកជុំវិញខ្លួន ។ ប្អូនស្រីរបស់នាងបាននិយាយថា៖ "គាត់លាក់ដែរមិនដែលបាននិយាយទេ គ្រាន់តែកាយវិការគាត់ចេញមក... ។" ប្អូនស្រីបានបន្តថា៖ "បើនិយាយទៅគាត់អត់ចង់ឲ្យបងប្អូនណាដឹងផង ។" នាងស្នាក់នៅជាមួយសាច់ញាតិប្តីរបស់នាង ហើយទោះបីជាពួកគេបានដឹងអំពីស្ថានភាព "ក៏ពួកគាត់ជួយសម្របសម្រួលរហូត ។" ប្អូនស្រីរបស់នាងបានបន្ថែម។*

*ដោយមិនអាចទទួលបានជំនួយពីអាជ្ញាធរនៅស្រុកកំណើតរបស់នាង ចាន់នីបានស្នើសុំជួបជាមួយអាជ្ញាធរឃុំនៅទីលំនៅថ្មីរបស់នាង ។ ជនល្មើសបានសម្លាប់នាងនៅថ្ងៃតែមួយដែលនាងបានទទួលដីកាកោះហៅដំបូង ។*

*ក្រោយមក ប្តីរបស់នាងត្រូវបានកាត់ទោសពីបទឃាតកម្ម អមដោយការធ្វើទារុណកម្ម ឬអំពើឃោរឃៅ តាមមាត្រា២០៥ នៃក្រមព្រហ្មទណ្ឌ ។ អង្គការលីកាដូមិនអាចដឹងនូវមូលហេតុពិតប្រាកដបាននោះទេដែលគាត់ត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល ១០ឆ្នាំ នៅខណៈដែលទោសអប្បបរមានៃបទល្មើសនេះ គឺជាប់ពន្ធនាគារអស់មួយជីវិត ។*

**ឈ្មោះត្រូវបានផ្លាស់ប្តូរ*

## ការព្យាយាមចាកចេញ៖ ការរារាំងដោយការផ្សះផ្សា

ការរក្សាភាពសុខដុមរមនាក្នុងជីវិតអាពាហ៍ពិពាហ៍ជាអាទិភាពចម្បងរបស់អាជ្ញាធរមូលដ្ឋាននិងតុលាការ នៅពេលឆ្លើយតបទៅនឹងអំពើហិង្សាក្នុងគ្រួសារ ។[២៤] អាជ្ញាធរនិងក្រុមគ្រួសារតែងតែដាក់សម្ពាធលើស្ត្រីឱ្យចូលរួមក្នុងការសម្រុះសម្រួលនិងផ្សះផ្សាជាមួយជនល្មើសម្តងហើយម្តងទៀត សូម្បីតែនៅពេលស្ត្រីកំពុងស្វែងរកការចែកផ្លូវឬយុត្តិធម៌ផ្នែកព្រហ្មទណ្ឌក៏ដោយ ។ ដំណើការសម្រុះសម្រួលទំនងជាមិនអនុវត្តតាមដំណើរការដែលបានកំណត់ណាមួយនោះទេ ប៉ុន្តែជារឿយៗតែងតែធ្វើឡើងដោយការមិនបានគិតគូរច្បាស់លាស់ ដើម្បីផ្សះផ្សាប្តីប្រពន្ធឱ្យត្រូវគ្នាវិញ ជាជាងការសម្រុះសម្រួលពិតប្រាកដ ការចូលរួមស្តីបន្ទោសជនរងគ្រោះ ការចូលរួម "អប់រំ" ជនល្មើសអំពីផលប៉ះពាល់នៃអំពើហិង្សាក្នុងគ្រួសារឬស្ត្រីអំពីរបៀបចៀសវាងពី "ជំរុញ" ឱ្យមានអំពើហិង្សា ឬការឱ្យភាគីទាំងពីរចុះកិច្ចសន្យាដោយប្តេជ្ញាថាផ្លាស់ប្តូរអាកប្បកិរិយារបស់ពួកគេ ។ ជានិច្ចកាល វិធានការទាំងនេះមិនបានបញ្ចប់អំពើហិង្សា និងមិនទទួលខុសត្រូវចំពោះហានិភ័យនៃអំពើហិង្សាធ្ងន់ធ្ងរដែលស្ត្រីបានប្រឈម បន្ទាប់ពីការបរិហារអំពីអាកប្បកិរិយាបំពានរបស់ដៃគូពួកគេ ។

**ស្ត្រី ៦នាក់**

ត្រូវទទួលបានការផ្សះផ្សាដោយអាជ្ញាធរ និងសមាជិកគ្រួសារ បន្ទាប់ពីអាកប្បកិរិយាបំពានរបស់ជនល្មើស

**ជនល្មើស 0នាក់**

ត្រូវបានរារាំងពីការប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារម្តងហើយម្តងទៀត

**ស្ត្រី 0នាក់**

អាចរស់នៅដោយមានសេរីភាព ពីការប្រើអំពើហិង្សាបន្ទាប់ពីទំនាក់ទំនងរបស់ត្រូវបាន "ផ្សះផ្សា"

ជនល្មើសបានចូលរួមក្នុងទម្រង់ជាច្រើននៃការផ្សះផ្សា ដោយសារអាប្បកិរិយាហិង្សារបស់ពួកគេ យ៉ាងតិចណាស់ ៦ ករណី ក្នុងចំណោម ២៦ ករណី ។ ក្នុងចំណោមករណីទាំងនេះ៖

- អាជ្ញាធរភូមិ អាជ្ញាធរឃុំ និង/ឬ នគរបាលបានព្យាយាមផ្សះផ្សាយ៉ាងតិចណាស់ក្នុង ៤ករណី ដោយ "អប់រំ" ជនល្មើស ធ្វើកិច្ចសន្យាឱ្យពួកគេបញ្ឈប់អំពើហិង្សា ឬ "ណែនាំ" ដល់ស្ត្រីដែលស្នើសុំឱ្យអាជ្ញាធរទាំងនោះជួយ ។ ករណីមួយក្នុងចំណោមករណីទាំងនេះ អាជ្ញាធរមិនទទួលបានជោគជ័យក្នុងការសម្រុះសម្រួលយ៉ាងតិចណាស់ ៤ដង ដាច់ដោយឡែកពីគ្នា ។
- យ៉ាងតិចណាស់ ១ករណី អាជ្ញាធរឃុំបានដឹងពីអំពើហិង្សាផ្លូវកាយធ្ងន់ធ្ងរ ។ អាជ្ញាធរទាំងនោះបានធ្វើកិច្ចព្រមព្រៀងលែងលះ ប៉ុន្តែជាជាងការផ្តល់ឱ្យស្ត្រីនូវមធ្យោបាយដែលមានសុវត្ថិភាពដើម្បីចែកផ្លូវគ្នា អាជ្ញាធរទាំងនោះអនុញ្ញាតឱ្យគ្រួសារជនសង្ស័យផ្សះផ្សាទំនាក់ទំនងប្តីប្រពន្ធ ។
- ក្នុងករណីមួយ ជនល្មើសបានចូលរួមការសម្រុះសម្រួលជាច្រើនលើកច្រើនសារ ក្នុងអំឡុងពេលជីវិតអាពាហ៍ពិពាហ៍មុនដោយសារតែអាកប្បកិរិយាហិង្សារបស់ជនល្មើស ។ ជនល្មើសមិនដែលទទួលខុសត្រូវ ហើយបន្តប្រព្រឹត្តអំពើហិង្សាលើប្រពន្ធក្រោយរបស់ខ្លួនដោយមិនមានទោសពៃ មុននឹងជននោះសម្លាប់នាង ។

[២៤] Katherine Brickell, "ភាពមិនច្បាស់លាស់នៃការវិនិច្ឆ័យច្បាប់អំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា៖ ការចោទប្រកាន់ជនរងគ្រោះដោយភាគីពាក់ព័ន្ធជាស្ថាប័ននៅក្នុងប្រទេសកម្ពុជា" ទស្សនាវដ្តីស្តីពីអំពើហិង្សាអន្តរបុគ្គល ៣២(៩) ទំព័រ១៣៦៣ ឆ្នាំ២០១៧ ។ គ្រី ស៊ុយហ៊ាង និងអ្នកនិពន្ធផ្សេងទៀត "ការរក្សាភាពសុខដុមរមនាឬការការពារយុត្តិធម៌? ការសិក្សាអំពីការអនុវត្តការដោះស្រាយវិវាទក្នុងមូលដ្ឋានក្នុងករណីអំពើហិង្សាក្នុងគ្រួសារនិងដៃគូស្និទ្ធស្នាលនៅកម្ពុជា" អង្គការនារីដើម្បីសន្តិភាព មជ្ឈមណ្ឌលសម្រុះសម្រួលវិវាទកម្ពុជា សហការជាមួយអង្គការក្លាហាន ទំព័រ៥ ខែតុលា ឆ្នាំ២០២០ ដកស្រង់ពី៖ https://wpmcambodia.org/project/preserving-harmony-or-preventing-justice/

កត្តាសេដ្ឋកិច្ចក៏ធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពរបស់ស្ត្រីក្នុងការស្វែងរកការលែងលះ ឬយុត្តិធម៌ផ្នែកព្រហ្មទណ្ឌផងដែរ ដោយសារការផ្សះផ្សាជាធម្មតាជាជម្រើសដែលចំណាយតិចជាងដំណើរការផ្លូវច្បាប់ ។

ទោះបីជាបរាជ័យម្តងហើយម្តងទៀតក្នុងការផ្សះផ្សា និងហានិភ័យនៃអំពើហិង្សាធ្ងន់ធ្ងរកាន់តែច្រើនឡើងចំពោះស្ត្រីនិងកុមារក៏ដោយ ក៏អាជ្ញាធរនៅតែបន្តព្យាយាមធ្វើការផ្សះផ្សាដដែល ។

គោលគំនិតនៃចំណងអាពាហ៍ពិពាហ៍ជាទូទៅ ត្រូវបានផ្តល់អាទិភាពជាងសុវត្ថិភាពរបស់ស្ត្រីទាំងនៅក្នុងសង្គមនិងច្បាប់ ។ ការសម្រុះសម្រួល និងការផ្សះផ្សាក្នុងសំណុំរឿងអំពើហិង្សាក្នុងគ្រួសារ ត្រូវបានគាំទ្រដោយក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ដែលច្បាប់នេះជាសម្បទានដល់សមាជិករដ្ឋសភាដែលបានចាត់ទុកការអនុម័តនៃច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារថាជា "បដិវត្តន៍សង្គម" ហើយបានស្នើឱ្យ "ច្បាប់នេះចែងឱ្យមានការសម្រុះសម្រួលមុននឹងពិចារណាលើការផ្តន្ទាទោស ។"[២៥]

ក្រមរដ្ឋប្បវេណី កំណត់ការលែងលះថាជាដំណោះស្រាយចុងក្រោយបំផុត៖ ការកំណត់នេះអនុញ្ញាតឱ្យអាជ្ញាធរឃុំ/សង្កាត់ និងតុលាការពន្យារពេលនីតិវិធីលែងលះ ដោយបញ្ចុះបញ្ចូលភាគីឱ្យឈានដល់ការសម្របសម្រួល "ទោះបីជាភាគីណាមួយទាមទារលែងលះយ៉ាងខ្លាំងក៏ដោយ ។"[២៦] បទពិសោធន៍របស់អង្គការលីកាដូក្នុងសំណុំរឿងមួយចំនួនដែលមិនត្រូវបានលើកឡើងនៅក្នុងរបាយការណ៍នេះ បានរកឃើញថាចៅក្រមរដ្ឋប្បវេណី តែងតែកោះហៅប្តីប្រពន្ធ ដើម្បីសម្រុះសម្រួលរហូតដល់ ២ ទៅ ៣ដង ដោយម្តងៗមានគម្លាតពីគ្នារយៈពេលជាច្រើន មុនយល់ព្រមលើការលែងលះ ។

ដូចគ្នានេះដែរ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ធ្វើការហាមឃាត់មិនគ្រប់គ្រាន់លើអំពើហិង្សាក្នុងគ្រួសារ និងអនុញ្ញាតឱ្យមានការសម្របសម្រួលក្នុងគោលបំណងផ្សះផ្សាប្តីប្រពន្ធនិងចៀសវាងការចែកផ្លូវគ្នា ។ តួអង្គដូចជាសាច់ញាតិ ព្រះសង្ឃ ព្រឹទ្ធាចារ្យ មេភូមិ ក្រុមប្រឹក្សាឃុំ និងតុលាការ ត្រូវបានអនុញ្ញាតឱ្យដើរតួជាអាជ្ញាកណ្តាលក្នុងការសម្របសម្រួល ដែលភាគច្រើនអ្នកទាំងនោះមិនទទួលបានការបណ្តុះបណ្តាលនោះទេ ។[២៧] អំពើហិង្សាលើផ្លូវអារម្មណ៍ ផ្លូវចិត្ត ឬសេដ្ឋកិច្ច ក៏ដូចជា "បទមជ្ឈិមកម្រិតស្រាល" ត្រូវបានអនុញ្ញាតឱ្យមានការសម្របសម្រួល ឬផ្សះផ្សាជាជាងការផ្តន្ទាទោស ប្រសិនបើមានការព្រមព្រៀងពីភាគីទាំងពីរ ។[២៨] ដោយសារមិនមាននិយមន័យនៃបទល្មើសលហុកម្រិត "ស្រាល" និង "ធ្ងន់" នៅក្នុងច្បាប់កម្ពុជា អាជ្ញាធរដែលមិនទទួលបានការបណ្តុះបណ្តាល ជាញឹកញាប់ជាអ្នកកំណត់ភាពធ្ងន់ធ្ងរនៃសកម្មភាពល្មើស ហើយកំណត់ថាតើអាចផ្សះផ្សាបានដែរឬទេ ។ បទដ្ឋានវប្បធម៌និងភាពលំអៀងផ្នែកយេនឌ័រ តែងតែកំណត់ការសម្រេចទាំងនេះដោយមានការផ្សះផ្សាដែលតែងកើតឡើងជាញឹកញាប់ ទោះបីជាក្នុងករណីមានអំពើហិង្សាធ្ងន់ធ្ងរកើតមានជាបន្តបន្ទាប់ក៏ដោយ ។

ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ មិនអនុញ្ញាតឱ្យមានការសម្រុះសម្រួលក្នុងករណីអំពើហិង្សាក្នុងគ្រួសារដែលកើតឡើងម្តងហើយម្តងទៀតនោះទេ ។ ប៉ុន្តែការកំណត់ថាអំពើនោះត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌ[២៩] និងការកម្រិតការផ្សះផ្សាប្រកបដោយប្រសិទ្ធភាពឱ្យតែមួយដង នៅក្នុងច្បាប់នោះ នៅតែកម្រត្រូវបានអាជ្ញាធរអនុវត្តបានណាស់ ។ អាជ្ញាធរតែងតែធ្វើការផ្សះផ្សាម្តងហើយម្តងទៀតទោះគ្មានប្រយោជន៍ ជាពិសេសអំពើហិង្សាដែលកើតឡើងជាបន្តបន្ទាប់ឬម្តងហើយម្តងទៀត ដែលមិនមែនជាសកម្មភាព "ធ្ងន់ធ្ងរ" តែមួយគត់ក៏ដោយ ដែលទង្វើនេះធ្វើឱ្យស្ត្រីប្រឈមនឹងអំពើហិង្សាជាបន្តបន្ទាប់ ។

[២៥] របាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តវេទិកាទីក្រុងប៉េកាំងសម្រាប់សកម្មភាពលើបញ្ហាស្ត្រីឆ្នាំ១៩៩៥-២០០៥" ទំព័រ១៤
[២៦] មាត្រា៩៨២(២) និង៩៨៤(១) នៃក្រមរដ្ឋប្បវេណី
[២៧] មាត្រា២៦-២៧ នៃច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ
[២៨] មាត្រា១៧ ២៦-២៧ នៃច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ
[២៩] មាត្រា៣៦ នៃច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ

## *អំពើហិង្សាដែលបង្កឡើងដោយការផ្សះផ្សា*

*វិច្ឆិកា* មានអាយុជាង ៣០ឆ្នាំ ប្រឈមនឹងអំពើហិង្សាផ្លូវកាយនិងផ្លូវភេទដែលប្រព្រឹត្តដោយអតីតដៃគូរបស់នាង មុនពេលនាងត្រូវបានសម្លាប់ ។ មិត្តភក្តិនិងសាច់ញាតិរបស់នាងបានដឹងពីទង្វើរំលោភបំពានរបស់ដៃគូនាង ។ បន្ទាប់ពីរស់នៅជាមួយគ្នាបានតែប៉ុន្មានខែ "គេ(អ្នកជិតខាង)ចេះតែប្រាប់ដែរ ថាឈប់យកតាហ្នឹងទៅ ប្រយត្ន័តាហ្នឹងសម្លាប់ចោលនៅថ្ងៃណាមួយនោះ" ។*

*ទោះបីជាប្ដីប្រពន្ធមិនទាន់រៀបការក៏ដោយ វិច្ឆិកាបានទៅរកអាជ្ញាធរភូមិដើម្បីស្នើសុំជំនួយ ដោយសារជនល្មើសប្រច័ណ្ឌហួសហេតុ ។ អាជ្ញាធរភាគច្រើនមិនអើពើនឹងនាងនោះទេ ។ មិត្តភក្តិរបស់នាងបាននិយាយថា៖ "មេភូមិគាត់ថាអឺ...ពិបាកណាស់ហ្អ៎ា ចំណាស់ៗហ្នឹងហើយ...ពិបាកណាស់ យើងដោះស្រាយ យើងលែង លែងយកគ្នាវិញដដែល ខ្ជិលណាស់ ។"*

*លោកអនុភូមិបានចូលរួមសម្របសម្រួលជាមួយប្ដីប្រពន្ធក្នុងគោលបំណងផ្សះផ្សាការយល់ច្រឡំរបស់ពួកគេ មុនពេលគាត់ឱ្យពួកគេត្រឡប់ទៅផ្ទះវិញ ។ គ្មានកិច្ចខិតខំប្រឹងប្រែងណាមួយត្រូវបានធ្វើឡើង ដើម្បីសម្របសម្រួលដល់ការចែកផ្លូវគ្នា ឬធានាសុវត្ថិភាពរបស់វិច្ឆិកាឡើយ ។ ភ្លាមៗនោះ ប្តីរបស់វិច្ឆិកាស្តីបន្ទោសនាងចំពោះការរាយការណ៍ពីករណីនេះទៅអាជ្ញាធរ ។ មិត្តភក្តិរបស់វិច្ឆិកាបាននិយាយថា៖ "[ក្នុងអំឡុងពេលពិភាក្សាគ្នា] មុខក្រម៉ូវហ្មង មុខខឹង គាត់ខឹង...រំលង២-៣ថ្ងៃសម្លាប់បាដោយ ។"*

*ជនល្មើសបានរត់គេចខ្លួន ហើយមិនទាន់ត្រូវបានអាជ្ញាធរចាប់ខ្លួននោះទេ ។ ប្អូនថ្លៃរបស់វិច្ឆិកាបាននិយាយថា "រឿងចាប់ឃាតករយកមកដាក់ទោស គឺយើងបន់ឲ្យតែចាប់ទេ ។" "កូនចៅគាត់បង្កើតមិនដឹងឈឺចាប់យ៉ាងណា ។"*

**ឈ្មោះត្រូវបានផ្លាស់ប្ដូរ*

## ការបរាជ័យនៃយន្តការការពារ

ពុំមានស្ត្រីណាម្នាក់ក្នុងចំណោមស្ត្រី ២៦នាក់ ដែលត្រូវបានសម្លាប់ ទទួលបានសិទ្ធិទទួលបានការការពារឬការជួយគ្រប់គ្រាន់មុនការស្លាប់របស់ពួកគេទេ ។ ក្នុងករណីខ្លះ ពួកគេប្រឈមនឹងឧបសគ្គចម្បងមួយចំនួនក្នុងការរាយការណ៍អំពីអំពើហិង្សា ។ ករណីខ្លះទៀត អាជ្ញាធរមិនបានឆ្លើយតបឱ្យបានគ្រប់គ្រាន់ នៅពេលដែលស្ត្រីទាំងនោះស្វែងរកជំនួយនោះទេ ។ យ៉ាងតិចណាស់ ស្ត្រី ៨នាក់ ក្នុងចំណោម ២៦នាក់ ត្រូវបានសម្លាប់បន្ទាប់ពីព្យាយាមបញ្ចប់ទំនាក់ទំនងឬបញ្ឈប់ការទាក់ទង ជាមួយដៃគូដែលប្រើអំពើហិង្សា ។ ការការពារនិងការផ្តល់ជំនួយដើម្បីចាកចេញពីទំនាក់ទំនងជាមួយដៃគូដោយសុវត្ថិភាព គឺចាំបាច់ក្នុងអំឡុងពេលដ៏មានសារៈសំខាន់នេះ ប៉ុន្តែស្ត្រីទាំងនោះមិនទទួលបាននោះឡើយ ។

ក្នុងចំណោមទាំង ២៦ករណី មានស្ត្រីយ៉ាងតិចណាស់ ៨នាក់ ត្រូវបានសម្លាប់បន្ទាប់ពីបានព្យាយាមនៅក្នុងករណីជាច្រើន ម្តងហើយម្តងទៀត ដើម្បីចាកចេញពីទំនាក់ទំនងដែលមានការរំលោភបំពាននោះ ។ ក្នុងចំណោមករណីទាំងនេះ៖

- យ៉ាងតិចណាស់ស្ត្រី ៥នាក់ បានស្វែងរកការលែងលះពីអាជ្ញាធរ ហើយយ៉ាងតិចណាស់ ៣នាក់ផ្សេងទៀតបានព្យាយាមបញ្ឈប់ទំនាក់ទំនងជាមួយដៃគូដែលប្រើអំពើហិង្សា ។
- បន្ទាប់ពីការព្យាយាមរបស់ស្ត្រីទាំងនោះដើម្បីចាកចេញពីទំនាក់ទំនង យ៉ាងតិចណាស់ស្ត្រី ៤នាក់ ក្នុងចំណោមនេះ បានក្លាយជាគោលដៅនៃការបៀតបៀនជាបន្តបន្ទាប់ ការតាមប្រម៉ាញ់ ឬការគំរាមកំហែងដល់អាយុជីវិត ។ ក្នុងករណីមួយក្នុងចំណោមករណីទាំងនេះ អាជ្ញាធរមិនបានផ្តល់ការការពារដល់ស្ត្រីឡើយ ខណៈប្តីរបស់នាងប៉ុនប៉ងសម្លាប់នាងជាច្រើនដង ។
- អាជ្ញាធរមូលដ្ឋានឬនគរបាលដឹងអំពីអំពើហិង្សាក្នុងគ្រួសារ ហើយអាចជួយស្ត្រីក្នុងការព្យាយាមចាកចេញ នៅក្នុងករណីយ៉ាងតិចណាស់ ៦ ក្នុងចំណោមករណីទាំងនេះ ប៉ុន្តែអាជ្ញាធរទាំងនោះជាក់ស្តែងមិនបានផ្តល់ជំនួយណាមួយដល់ស្ត្រីទាំងនោះឡើយ ។



**ស្ត្រី ៨នាក់**

ត្រូវបានសម្លាប់ បន្ទាប់ពីព្យាយាមចាកចេញពីជីវិតអាពាហ៍ពិពាហ៍ ឬទំនាក់ទំនង



**ស្ត្រី 0នាក់**

បានទទួលការការពារគ្រប់គ្រាន់

ការធានាសុវត្ថិភាពរបស់ស្ត្រីតាមរយៈការទទួលបានយន្តការដូចជាទីជម្រកនិងដីកាការពារ គឺជាផ្នែកមួយនៃកាតព្វកិច្ចរបស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងគ្រប់ទម្រង់នៃការរើសអើងលើស្ត្រី ក្រោមអនុសញ្ញាស្តីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងលើស្ត្រី (អនុសញ្ញា CEDAW) ។[៣០] ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ បង្កើតវិធានការសុវត្ថិភាពជាមូលដ្ឋានមួយចំនួនសម្រាប់ស្ត្រីដែលចាកចេញពីអំពើហិង្សាក្នុងគ្រួសារ ដូចជាការសម្រេចចិត្តផ្នែករដ្ឋបាលឬដីកាការពារ ជាដើម ។ អាជ្ញាធរឃុំចេញសេចក្តីសម្រេចរដ្ឋបាល ដើម្បីហាមឃាត់ជនល្មើសមិនឱ្យចូលជិតផ្ទះឬកន្លែងធ្វើការ ។[៣១] ក្នុងអំឡុងពេលដំណើរការផ្លូវច្បាប់ តុលាការអាចចេញដីកាការពារ ដែលអាចហាមឃាត់ជនល្មើសពីការទាក់ទងជាមួយអ្នកប្តឹងតវ៉ាឬការលក់ទ្រព្យសម្បត្តិរួមនិងអនុវត្តការសម្រេចចិត្តបណ្តោះអាសន្នលើការចិញ្ចឹមមើលថែកុមារ និងកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ក្នុងចំណោមការការពារផ្សេងទៀត ។[៣២] ការរំលោភលើដីកាការពារគឺជាហេតុផលសម្រាប់ការចាប់ខ្លួនភ្លាមៗ ។[៣៣]

ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២១ កម្ពុជាបានរាយការណ៍ថាដីកាការពារចំនួនតែ២៥ ប៉ុណ្ណោះ បានចេញនៅទូទាំងប្រទេស ។[៣៤] រាជរដ្ឋាភិបាលមិនបានពន្យល់ពីមូលហេតុនៃការចេញដីកាការពារដែលមានចំនួនតិច ឬរាយការណ៍អំពីប្រសិទ្ធភាពរបស់វានោះទេ ។ តាមបទពិសោធន៍របស់អង្គការលីកាដូ បានបង្ហាញថាអាជ្ញាធរកម្រផ្តល់ដំណឹងដល់ស្ត្រីថាពួកគេមានសិទ្ធិទទួលបានការការពារទាំងនេះនោះណាស់ ដោយមិនគិតទាំងការលើកទឹកចិត្តឱ្យប្រើប្រាស់ ឬធានាថាវិធានការទាំងនោះនឹងត្រូវបានអនុវត្ត ។

ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ក៏តម្រូវឱ្យអាជ្ញាធរផ្តល់ទីជម្រកបណ្តោះអាសន្ន ដែលធានាបាននូវសុវត្ថិភាពដែរ ។[៣៥] ទោះជាយ៉ាងណាក៏ដោយ រយៈពេល ១៨ឆ្នាំ ក្រោយការចូលជាធរមាន មិនមានភស្តុតាងបញ្ជាក់ថា រាជរដ្ឋាភិបាលបានផ្តល់មូលនិធិបង្កើតទីជម្រកសុវត្ថិភាពនៅកម្ពុជានោះទេ ។ ទីជម្រកដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាថាស្ត្រីនិងកុមារ អាចទទួលបានលំនៅដ្ឋានប្រកបដោយសុវត្ថិភាព ការប្រឹក្សាយោបល់ និងជំនួយ ។ ដោយសារទីជម្រកដែលគ្រប់គ្រងនិងដំណើរការដោយរដ្ឋាភិបាលនៅទូទាំងពិភពលោក ជារឿយៗមានភាពខ្វះចន្លោះក្នុងការផ្តល់សេវាកម្មរបស់ខ្លួន[៣៦] ប្រព័ន្ធបញ្ជូនទៅកាន់ទីជម្រកឯករាជ្យនិងគ្រប់គ្រាន់គឺចាំបាច់ណាស់ ។ ការថែទាំចម្បង ការផ្តល់មូលនិធិគ្រប់គ្រាន់ និងការត្រួតពិនិត្យឯករាជ្យ ត្រូវបានទាមទារ ដើម្បីធានាថាទីជម្រកគ្រប់គ្រាន់ មិនមែនជាកន្លែងឃុំឃាំង រនាំងការពារដែលរំលោភសិទ្ធិសេរីភាពរបស់ស្ត្រីនោះឡើយ ហើយពិតជាលើកកម្ពស់តម្រូវការនិងបំណងប្រាថ្នារបស់ស្ត្រីនិងកុមារ ។

ជាចុងក្រោយ ឧបសគ្គផ្នែកហិរញ្ញវត្ថុជារឿយៗរារាំងស្ត្រីមិនឱ្យចាកចេញពីស្ថានភាពហិង្សា ។ កាតព្វកិច្ចអន្តរជាតិចង្អុលបង្ហាញពីតម្រូវការពីរាជរដ្ឋាភិបាលក្នុងការផ្តល់ការការពារដល់ជនរងគ្រោះ "ដោយមិនតម្រូវឱ្យមានការបំពេញលក្ខខណ្ឌផ្នែកហិរញ្ញវត្ថុ និងសេវារដ្ឋបាលអ្វីនោះទេ" ដើម្បីធានាលទ្ធភាពទទួលបានជំនួយផ្នែកហិរញ្ញវត្ថុនិងសម្របសម្រួលផ្តល់ឱកាសការងារ ។[៣៧] ស្ត្រីដែលចាកចេញពីអំពើហិង្សានៅក្នុងប្រទេសកម្ពុជា បច្ចុប្បន្នមិនមានសិទ្ធិទទួលបានជំនួយទាំងនេះណាមួយឡើយ ។

---

[៣០] សូមមើលរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីអំពើហិង្សាលើស្ត្រី មូលហេតុ និងផលវិបាក A/HRC/៣៥/៣០ កថាខណ្ឌទី១៩-២០

[៣១] មាត្រា១៤ នៃច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ

[៣២] មាត្រា២០-២៥ នៃច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ

[៣៣] មាត្រា១៨ នៃច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ

[៣៤] ព័ត៌មានដែលទទួលបានពីប្រទេសកម្ពុជា ស្តីពីការសង្កេតបញ្ចប់លើរបាយការណ៍ទី៦ នៃការត្រួតពិនិត្យឡើងវិញតាមពេលវេលាកំណត់របស់ប្រទេសកម្ពុជា
គណៈកម្មាធិការ CEDAW CEDAW/C/KHM/FCO/៦ កថាខណ្ឌទី៣០ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២២ ដកស្រង់ពី៖ https://documents-dds-ny.un.org/doc/UNDOC/GEN/N22/342/20/PDF/N2234220.pdf?OpenElement

[៣៥] មាត្រា១៣ នៃច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ

[៣៦] របាយការណ៍របស់អ្នករាយការណ៍ពិសេស ស្តីពីអំពើហិង្សាប្រឆាំងនឹងស្ត្រី មូលហេតុ និងផលវិបាក A/HRC/៣៥/៣០ កថាខណ្ឌ ៥៦

[៣៧] ប្រភពដូចយោងខាងលើ ខថាខណ្ឌទី១១២(ឃ) អនុសាសន៍ទូទៅលេខ៣៣ គណៈកម្មាធិការ CEDAW CEDAW/C/GC/៣៣ កថាខណ្ឌ ១៦(ខ) ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៥ https://tbinternet.ohchr.org/_layouts/15/treatybodyexternal/Download.aspx?symbolno=CEDAW%2FC%2FGC%2F33&Lang=en អនុសាសន៍ទូទៅលេខ៣៥ គណៈកម្មាធិការ CEDAW CEDAW/C/GC/៣៥ កថាខណ្ឌ ៤០(គ) ១៤ កក្កដា ២០១៧ ដកស្រង់ពី៖ https://tbinternet.ohchr.org/Treaties/CEDAW/Shared%20Documents/1_Global/CEDAW_C_GC_35_8267_E.pdf

## ការស្លាក់ស្មើរក្នុងការធ្វើសកម្មភាព

បុប្ផា* ជាស្ត្រីមានវ័យជាង ៣០ឆ្នាំ និងកូនប្រុសរបស់នាង ៤នាក់ ត្រូវបានសម្លាប់នៅផ្ទះរបស់ពួកគេ ។ ប្តីរបស់បុប្ផាធ្លាប់ប្រើអំពើហិង្សាលើកូនជាប្រចាំតាំងពីរៀបការរួច ។ ម្តាយរបស់បុប្ផាបាននិយាយថា "កូនប្រសារខ្ញុំពេលនៅនេះ ឲ្យតែវាវ៉ៃចៅខ្ញុំម្តងៗ វាតែងតែមានពាក្យនិយាយអញ្ចេះ ពាក្យដដែលៗ វាថាបើសិនជាវាលែង វាលែងម៉ាពូជ តាវាសម្លាប់ សម្លាប់ម៉ាពូជ ។"

ម្តាយរបស់បុប្ផាបានប្តឹងមេភូមិដោយផ្ទាល់មាត់អំពីអំពើហិង្សា ហើយស្នើសុំអាជ្ញាធរជួយសរសេរពាក្យបណ្តឹងផ្លូវការជាលាយលក្ខណ៍អក្សរ និងដាក់ពាក្យបណ្តឹងជំនួសនាង ដោយសារនាងមិនអាចអានឬសរសេរអក្សរ ។ មេភូមិបានច្រានចោលសំណើរបស់នាងដោយបញ្ជាក់ថា នាងគួរតែជាអ្នកដាក់ពាក្យបណ្តឹងផ្លូវការដោយខ្លួនឯង ។ ម្តាយរបស់បុប្ផាបាននិយាយថា "ដល់ពេលយើងប្តឹងអីអញ្ចឹង គាត់ឆ្លើយថាអីចេះ អញអត់ដឹងទេៗ អញរវល់នេះ អញរវល់នោះ ។" សូម្បីតែបន្ទាប់ពីញាតិសាច់ឆ្ងាយម្នាក់បានធ្វើដំណើរទៅភូមិដើម្បីសរសេរពាក្យបណ្តឹងផ្លូវការក៏ដោយ ក៏មិនមានវិធានការនិងការការពារណាមួយដល់បុប្ផាឬកូនៗរបស់នាងទេ ។ ម្តាយរបស់នាងបន្ទោសភាពអសកម្មនេះ ដោយហេតុថាជនល្មើសមានសាច់ញាតិនៅស្នងការដ្ឋាននគរបាលខេត្ត ។

នៅពេលគ្រួសារកាន់កាប់ទ្រព្យសម្បត្តិដ៏មានតម្លៃ ប្តីប្រពន្ធតែងតែឈ្លោះប្រកែកគ្នាជាញឹកញាប់ ថាតើគួរតែលក់ឬអត់ ។ បុប្ផាត្រូវបានសម្លាប់ជាមួយកូនមួយរំពេច ហើយជនល្មើសបានព្យាយាមរត់គេចខ្លួនជាមួយនឹងទ្រព្យសម្បត្តិ ។

សូម្បីតែបន្ទាប់ពីក្រុមគ្រួសារត្រូវបានសម្លាប់ក៏ដោយ ម្តាយរបស់នាងបានលើកឡើងថា មេភូមិបានព្យាយាមបំភាន់ការស៊ើបអង្កេតដោយអះអាងថា ជនល្មើសមិនមានជាប់ពាក់ព័ន្ធនឹងការស្លាប់របស់ពួកគេទេ ។ សាច់ញាតិរបស់ជនល្មើសស្ថិតក្នុងចំណោមមន្ត្រីនគរបាលដែលត្រូវបានបញ្ជូនទៅស៊ើបអង្កេតការស្លាប់ ។ ក្រោយមក ជនល្មើសត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត ប៉ុន្តែគ្រួសាររបស់បុប្ផាជឿថាមានអ្នកសមគំនិតផ្សេងទៀតដែលមិនបានទទួលខុសត្រូវ ។ ជនល្មើសបានប្តឹងឧទ្ធរណ៍លើសាលក្រមនេះហើយ ប៉ុន្តែមិនទាន់មានសវនាការនៅឡើយទេមកដល់ខែមករា ឆ្នាំ២០២៣ នេះ ។

*ឈ្មោះត្រូវបានផ្លាស់ប្តូរ

# សេចក្តីសន្និដ្ឋាន

អំពើហិង្សាក្នុងគ្រួសារមិនត្រូវបានទប់ស្កាត់ ឬផ្តន្ទាទោសប្រកបដោយប្រសិទ្ធភាពនៅឡើយ នៅក្នុងប្រទេសកម្ពុជា ។ ក្នុងនាមជាភាគីនៃអនុសញ្ញា CEDAW តាំងពីឆ្នាំ១៩៩២ មក រាជរដ្ឋាភិបាលបានប្តេជ្ញាជាបន្តបន្ទាប់អនុវត្ត "តាមគ្រប់មធ្យោបាយនិងដោយមិនពន្យារពេលចំពោះគោលនយោបាយលុបបំបាត់ការរើសអើងលើស្ត្រី ។"[៣៨] គណៈកម្មាធិការ CEDAW បានទទួលស្គាល់ថាវិសមភាពយេនឌ័រនិងអំពើហិង្សាអាចជាលទ្ធផលផ្ទាល់នៃការបរាជ័យរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តវិធានច្បាប់ពាក់ព័ន្ធ ។[៣៩] កម្ពុជានៅតែបរាជ័យលើបញ្ហាទាំងពីរ ។

នៅឆ្នាំ២០២០ ទីស្តីការគណៈរដ្ឋមន្ត្រីបានអនុម័តផែនការសកម្មភាពជាតិលើកទី៣ ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រីឆ្នាំ២០១៩-២០២៣ (NAPVAWIII) ហើយការអនុវត្តផែនការសកម្មភាពនេះ គឺមិនទាន់គ្រប់គ្រាន់នៅឡើយនៅក្នុងករណីជាច្រើន ។ ក្រោមការតាក់តែងនិងការអនុវត្តរបស់ក្រសួងកិច្ចការនារី ផែនការនេះមានគោលបំណង "បង្កើនសមត្ថភាពនិងពង្រីកកិច្ចខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយនិងឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី ។"[៤០] យុទ្ធសាស្ត្រនៃផែនការសកម្មភាពនេះរួមមានការការពារតាមរយៈយុទ្ធនាការព័ត៌មាន "គំរូការអនុវត្តល្អ" សម្រាប់បណ្តាញទូរស័ព្ទបន្ទាន់ និងទីជម្រក និងការត្រួតពិនិត្យឡើងវិញនូវច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ឆ្នាំ២០០៥។[៤១] ការអនុវត្តផែនការនេះ អាស្រ័យលើថវិកាជាតិកម្ពុជានិងមូលនិធិពីម្ចាស់ជំនួយ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ។[៤២] គ្មានភស្តុតាងច្បាស់លាស់នៃសកម្មភាពជាក់លាក់នៅក្រោម NAPVAW III ដែលទទួលបានមូលនិធិពីថវិកាជាតិទេ[៤៣] ហើយមិនមានសញ្ញាអំពីការវិវឌ្ឍនៃការអនុវត្តយុទ្ធសាស្ត្រទាំងនេះដែរ ។

ស្ត្រីនិងកុមារនៅកម្ពុជា នៅតែត្រូវបានបន្តរំលោភសិទ្ធិនិងមិនអើពើ។ ជាញឹកញាប់ ត្រូវបញ្ចប់ដោយមរណភាពរបស់ស្ត្រី ដែលប្រព្រឹត្តដោយដៃគូបច្ចុប្បន្នឬអតីតដៃគូរបស់នាង ។ ការព្រងើយកន្តើយរបស់ស្ថាប័ន ច្បាប់ដែលអនុគ្រោះដល់អំពើហិង្សាក្នុងគ្រួសារ និងវប្បធម៌ដ៏ស្មុគស្មាញនៃភាពស្ងៀមស្ងាត់នៅពេលមានអំពើហិង្សានៅតែបន្តមាននៅក្នុងប្រទេស ។ ស្ត្រីត្រូវបានរារាំងពីការរាយការណ៍អំពីអំពើហិង្សាក្នុងគ្រួសារ ដោយសារកត្តាវប្បធម៌ សង្គម និងសេដ្ឋកិច្ចផ្សេងៗគ្នា ។ វាជារឿងសំខាន់ដែលនៅពេលពួកគេរាយការណ៍ អាជ្ញាធរត្រូវមានឆន្ទៈក្នុងការផ្តល់ការការពារដល់ពួកគេ ដែលនេះត្រូវបានធានានៅក្រោមច្បាប់ជាតិ ។ ការស្ទង់មតិថ្នាក់ជាតិបានគូសបញ្ជាក់រួចហើយថាភាគច្រើននៃស្ត្រីដែលជួបប្រទះការរំលោភបំពាន មិនបានរាយការណ៍ពីស្ថានភាពរបស់ពួកគេ តាមរយៈបណ្តាញផ្លូវការទេ ។ ប្រសិនបើគ្មានការធ្វើអន្តរាគមន៍ខ្លាំងនិងបទប្បញ្ញត្តិដែលស៊ីសង្វាក់គ្នានោះទេ ប្រព័ន្ធរាយការណ៍នៅតែបន្តធ្វើឱ្យស្ត្រីជួបប្រទះអំពើហិង្សាកាន់តែធ្ងន់ធ្ងរ ។

ក្នុងករណីជាច្រើន អាជ្ញាធរមានព័ត៌មានគ្រប់គ្រាន់ ដើម្បីធ្វើអន្តរាគមន៍និងទប់ស្កាត់ការស្លាប់របស់ស្ត្រីនិងកុមារ ។ ស្ថានភាពរំលោភបំពានរបស់ពួកគេត្រូវបានរាយការណ៍ដោយផ្ទាល់ឬបានដឹងជាសាធារណៈ ។ កង្វះមូលនិធិថ្នាក់ជាតិរារាំងលទ្ធភាពក្នុងការផ្តល់ទីជម្រកសុវត្ថិភាព ដើម្បីបំពេញតម្រូវការលំនៅដ្ឋានប្រកបដោយសុវត្ថិភាពនិងការប្រឹក្សាយោបល់នៅក្នុងប្រទេស ។ អន្តរាគមន៍និងវិធានការការពារដែលចែងដោយច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារកម្រត្រូវបានអនុវត្ត សូម្បីតែក្នុងករណីមានអំពើហិង្សាធ្ងន់ធ្ងរនិងកំពុងបន្តក៏ដោយ ។ ការសម្របសម្រួលនិងការផ្សះផ្សាជាញឹកញាប់នៅតែជាវិធីសាស្ត្រដែលអាជ្ញាធរតែងតែជ្រើសរើស ។ បញ្ហាទាំងនេះត្រូវបានបដិសេធម្តងហើយម្តងទៀត[៤៤] ប៉ុន្តែមិនទាន់គ្រប់គ្រាន់ក្នុងការដោះស្រាយនោះឡើយ ។

អំពើពុករលួយ ភាពចន្លោះប្រហោងនៃច្បាប់ និងការពង្រឹងបទដ្ឋានយេនឌ័របន្តធ្វើឱ្យប៉ះពាល់ដល់ការតស៊ូរបស់ស្ត្រីដើម្បីសុវត្ថិភាពនិងការគោរពសិទ្ធិរបស់ពួកគេ ។ សិទ្ធិរបស់ស្ត្រីគ្រប់រូបក្នុងការរស់នៅដោយគ្មានអំពើហិង្សា និងគ្មានការរារាំងដើម្បីទទួលបានយុត្តិធម៌ គឺជាសិទ្ធិមនុស្សជាមូលដ្ឋាន ។ ពុំគួរព្រងើយកន្តើយចំពោះពួកគេទៀតទេ ។

---

[៣៨] មាត្រា២ នៃអនុសញ្ញាស្តីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (អនុសញ្ញា CEDAW) មាត្រា៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តក្នុងការ "ទទួលស្គាល់និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញានិងអនុសញ្ញានានាទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រីនិងកុមារ ។"

[៣៩] អនុសាសន៍ទូទៅលេខ២៨ គណៈកម្មាធិការ CEDAW CEDAW/C/GC/២៨ កថាខណ្ឌ១០ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១០ ដកស្រង់ពី៖ https://documents-dds-ny.un.org/doc/UNDOC/GEN/G10/472/60/PDF/G1047260.pdf?OpenElement

[៤០] ផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ (NAPVAW III) ទំព័រ៩ ឆ្នាំ២០២០ ដកស្រង់ពី៖ https://www.mowa.gov.kh/wp-content/uploads/2021/01/NAP_2019-2023_English.pdf

[៤១] ប្រភពដូចយោងខាងលើ ទំព័រ១០-១៩ ៣០-៣២ ៣៥

[៤២] ប្រភពដូចយោងខាងលើ ទំព័រ៤២

[៤៣] "ការតាមដានការបញ្ជូនបន្តដោយគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា លើ CEDAW (NGO-CEDAW" ស្តីពីអនុសាសន៍ដែលបានរៀបចំសម្រាប់កម្ពុជា ដោយគណៈកម្មាធិការ CEDAW ក្នុងខែវិច្ឆិកា ឆ្នាំ២០១៩ NGO-CEDAW ទំព័រ៤ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ ដកស្រង់ពី៖

https://tbinternet.ohchr.org/_layouts/15/treatybodyexternal/Download.aspx?symbolno=INT%2FCEDAW%2FNGO%2FKHM%2F48951&Lang=en

[៤៤] សូមមើលរបាយការណ៍របស់អង្គការលីកាដូ "គ្មានការផ្តន្ទាទោស គ្មានការការពារ៖ ការឆ្លើយតបរបស់កម្ពុជាចំពោះអំពើហិង្សាក្នុងគ្រួសារ" ទំព័រ២០ ខែធ្នូ ឆ្នាំ ២០១៧ ដកស្រង់ពី៖ https://www.licadho-cambodia.org/reports.php?perm=225

# អនុសាសន៍ចំពោះរាជរដ្ឋាភិបាល

- បង្កើតបរិយាកាសអំណោយផលដែលស្ត្រីអាចរាយការណ៍អំពីអំពើហិង្សាក្នុងគ្រួសារដោយសុវត្ថិភាពនិងឯករាជ្យ។
    - អនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលតម្រូវឱ្យអាជ្ញាធរធ្វើអន្តរាគមន៍ភ្លាមៗនិងបញ្ជូនរបាយការណ៍ពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារ ឧក្រិដ្ឋកម្ម ឬបទមជ្ឈិមទតុលាការ ។
    - រៀបចំគោលនយោបាយគាំពារសង្គមយ៉ាងទូលំទូលាយ ដើម្បីដកចេញនូវសម្ពាធហិរញ្ញវត្ថុ ដែលអាចរារាំងស្ត្រីពីការបន្តការកាត់ទោសព្រហ្មទណ្ឌ ដំណើរការលែងលះរដ្ឋប្បវេណី ឬការបែកផ្លូវគ្នា ។
    - ត្រូវប្រាកដថាអាជ្ញាធរមូលដ្ឋាននិងនគរបាល ជូនដំណឹងដល់ស្ត្រីអំពីសិទ្ធិនិងជម្រើសផ្លូវច្បាប់របស់ពួកគេ រួមទាំងសិទ្ធិរបស់ពួកគេចំពោះដីកាការពារនិងការសម្រេចចិត្តផ្នែករដ្ឋបាល ហើយធានាថាច្បាប់និងដីកាទាំងនេះត្រូវបានអនុវត្តយ៉ាងពេញលេញ ។
- ត្រួតពិនិត្យឡើងវិញឱ្យបានទូលំទូលាយនិងធ្វើវិសោធនកម្មច្បាប់ដែលមានស្រាប់ ស្តីពីអំពើហិង្សាក្នុងគ្រួសារ ដើម្បីលុបបំបាត់របាំងរវាងស្ត្រី សុវត្ថិភាព និងយុត្តិធម៌ ។
    - ធ្វើវិសោធនកម្មច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងក្រមរដ្ឋប្បវេណី ដើម្បីដកចេញនូវបទប្បញ្ញត្តិទាំងឡាយណា ដែលអនុញ្ញាតឬលើកទឹកចិត្តឱ្យមានការសម្របសម្រួលឬការផ្សះផ្សាករណីអំពើហិង្សាក្នុងគ្រួសារ ដោយមិនគិតពីភាពធ្ងន់ធ្ងរនៃអំពើល្មើសឡើយ ។
    - បញ្ចូលដំណើរការច្បាស់លាស់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីធានាថា ដីកាការពារចេញបានទាន់ពេលវេលា និងដោយមិនដាក់បន្ទុកបន្ថែមលើស្ត្រីនិងគ្រួសាររបស់ពួកគេ ។
    - ផ្តល់និយមន័យផ្លូវច្បាប់ឱ្យទូលំទូលាយនិងការពិន័យទៅលើអំពើហិង្សាផ្លូវកាយ ផ្លូវអារម្មណ៍ ផ្លូវភេទ និងសេដ្ឋកិច្ច នៅក្រោមក្រមព្រហ្មទណ្ឌ និងរួមបញ្ចូលការលើកឡើងនៃមាត្រាថ្មីទាំងនេះ ក្នុងច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ។ ដកភាពខុសគ្នារវាងបទមជ្ឈិម "ស្រាល" និង "ធ្ងន់" ចេញពីច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ។
    - ធានាសុវត្ថិភាពរបស់ស្ត្រីដែលរាយការណ៍អំពីអំពើហិង្សាក្នុងគ្រួសារ ដោយឆ្លើយតបភ្លាមៗ ចំពោះសំណើអន្តរាគមន៍របស់ស្ត្រីនិងកុមារ និងធានាការការពារពីជនល្មើស ក្នុងអំឡុងពេលស៊ើបអង្កេតនីមួយៗ ។
    - បង្កើតគោលការណ៍ច្បាស់លាស់ ឬគោលការណ៍ណែនាំអំពីនីតិវិធីដើម្បីរំលាយចំណងអាពាហ៍ពិពាហ៍ដែលមិនបានចុះបញ្ជី ដោយមិនតម្រូវឱ្យមានវត្តមាននិងការយល់ព្រមពីភាគីទាំងពីរ ។
- រៀបចំផែនការ បង្កើត និងផ្តល់ហិរញ្ញប្បទានយ៉ាងទូលំទូលាយដល់ប្រព័ន្ធជាតិនៃការបញ្ជូនទៅកាន់ទីជម្រកសម្រាប់ស្ត្រីនិងកុមារដែលជួបប្រទះអំពើហិង្សាក្នុងគ្រួសារ ធានាឯករាជ្យភាពវិជ្ជាជីវៈ និងការសម្ងាត់របស់ពួកគេ និងធានាថាពួកគេមិនមានការរំលោភសិទ្ធិ ឬឯករាជ្យភាពរបស់ស្ត្រីបន្ថែមទៀត ។
- ប្រតិបត្តិជាប្រព័ន្ធនិងផ្សព្វផ្សាយជាប្រចាំនូវការស្រាវជ្រាវនិងស្ថិតិស្តីពីអត្រាការកើតមានជាទូទៅនៃអំពើហិង្សាក្នុងគ្រួសារក្នុងប្រទេសកម្ពុជា រួមទាំងចំនួនករណីដែលបានរាយការណ៍ទៅអាជ្ញាធរនិងលទ្ធផល ។ ចងក្រងជាឯកសារយ៉ាងទូលំទូលាយអំពីអត្រាកើតមានជាទូទៅនៃការរំលោភបំពានដែលមិនបានរាយការណ៍ ។
- បង្វែរទិសដៅថវិការយៈពេលវែងគ្រប់គ្រាន់ពីថវិកាជាតិទៅ NAPVAW III និងគម្រោងផ្សេងទៀត ដែលសម្របសម្រួលដោយក្រសួងកិច្ចការនារី ដើម្បីដកការពឹងផ្អែកលើការគាំទ្រពីខាងក្រៅ ។
- លើកកម្ពស់ការយល់ដឹងអំពីការមិនអាចទទួលយកបាននៃអំពើហិង្សាក្នុងគ្រួសារក្នុងគ្រប់ទម្រង់របស់វា ឫសគល់នៃបទដ្ឋានយេនឌ័រ និងការគំរាមកំហែងដែលតែងតែបង្កឡើងដល់ជីវិតស្ត្រីនិងកុមារ ។
- ផ្សព្វផ្សាយគំនិតដែលថា អំពើហិង្សាក្នុងគ្រួសារគឺជាការគំរាមកំហែងដល់ជីវិតអាពាហ៍ពិពាហ៍និងសហគមន៍ ហើយថាការសន្ទនាមិនអាចការពារស្ត្រីនិងកុមាពីអំពើហិង្សាបន្ថែមបានទេ ៕